វិទ្យាស្ថាន ពាណិជ្ជសាស្ត្រ អេស៊ីលីដា
អេស៊ីលីដា
ACLEDA
ACLEDA INSTITUTE OF BUSINESS

# វិទ្យាស្ថាន ពាណិជ្ជសាស្ត្រ អេស៊ីលីដា

ផ្តល់អប់រំដើម្បីភាពជោគជ័យក្នុងអនាគត

















# របាយការណ៍ប្រចាំឆ្នាំ

# ២០១៧

វិទ្យាស្ថាន ពាណិជ្ជសាស្ត្រ អេស៊ីលីដា

ACLEDA INSTITUTE OF BUSINESS

ផ្ចាលអប់រំដើម្បីភាពជោគជ័យក្នុងអាជីព

# ថ្នាក់បរិញ្ញាបត្រ

# ថ្នាក់បរិញ្ញាបត្ររងឯកទេស

## ជំនាញហិរញ្ញវត្ថុ និង ធនាគារ

- ✓ ចុះហាត់ការផ្ទាល់ នៅធនាគារ អេស៊ីលីដា
- ✓ ឱកាសទទួលបានអាហារូបករណ៍ និង រង្វាន់សិក្សា
- ✓ សិក្សាជាមួយសាស្ត្រាចារ្យដែលមានចំណេះជំនាញ និង វិជ្ជាជីវៈច្បាស់លាស់
- ✓ អាទិភាពខ្ពស់ក្នុងដំណើរការជ្រើសរើសចូលបម្រើការងារជាមួយក្រុមហ៊ុនដៃគូ
- ✓ បរិយាកាសនៃការសិក្សាល្អ ជាមួយនឹងសិក្ខូបករណ៍ទំនើបទាន់សម័យ




១០០ % + ៤៨០០ ដុល្លារ

១០០ %

៥០ %

២៥ %

១០ %

## ផ្តល់អាហារូបករណ៍សម្រាប់រយៈពេល៤ឆ្នាំ

## គុណភាព ក្រមសីលធម៌ ការងារ វិជ្ជាជីវៈ

**វិទ្យាស្ថាន ពាណិជ្ជសាស្ត្រ អេស៊ីលីដា** បានទទួលស្គាល់ដោយអនុក្រឹត្យ ពីរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា លេខ: ១៣ អនក្រ.បក ចុះថ្ងៃទី២៥ ខែមករា ឆ្នាំ២០១៦ សម្រាប់ការបណ្តុះបណ្តាលកម្រិត បរិញ្ញាបត្ររង បរិញ្ញាបត្រ និង បរិញ្ញាបត្រជាន់ខ្ពស់ លើដេប៉ាតឺម៉ង់គ្រប់គ្រងពាណិជ្ជកម្ម ជំនាញហិរញ្ញវត្ថុ និង ធនាគារ

អគារលេខ១៣៩៧ មហាវិថីមិត្តភាព ភ្នំពេញ-ហាណូយ ភូមិអន្លង់ក្ងាន សង្កាត់ឃ្មួញ ខណ្ឌសែនសុខ រាជធានីភ្នំពេញ

០២៣ ៩៨៦ ៩៣៧ / ០១៥ ៦០០ ១៨៥ / ០១០ ៣០០ ៨៧៩ / ០១៥ ៦០០ ៤១០

www.acleda-aib.edu.kh    info@acleda-aib.edu.kh    ACLEDA INSTITUTE OF BUSINESS

# ចក្ខុវិស័យ និងបេសកកម្ម

## ចក្ខុវិស័យ

វិទ្យាស្ថាន ពាណិជ្ជសាស្ត្រ អេស៊ីលីដា ជាថ្នាលអប់រំធុរកិច្ចប្រកបដោយគុណភាពឈានមុខ រួមចំណែកអភិវឌ្ឍសេដ្ឋកិច្ចកម្ពុជា និងតំបន់ ។

## បេសកកម្ម

បេសកកម្មរបស់ វិទ្យាស្ថាន ពាណិជ្ជសាស្ត្រ អេស៊ីលីដា គឺផ្តល់នូវសេវាកម្មអប់រំ និងបណ្តុះបណ្តាលវិជ្ជាជីវៈធុរកិច្ចតាមរយៈការអភិវឌ្ឍ៖ ចំណេះដឹង ជំនាញវិជ្ជាជីវៈ បទពិសោធន៍ អភិសមាចារ បណ្តាញទំនាក់ទំនង ដើម្បីជោគជ័យក្នុងអាជីពរបស់អ្នកសិក្សា ដោយប្រកាន់ខ្ជាប់ជានិច្ចនូវគោលការណ៍ សីលធម៌វិជ្ជាជីវៈ សង្គម វប្បធម៌ចម្រុះ ច្បាប់ និងបរិស្ថានប្រកបដោយកម្រិតខ្ពស់បំផុត ។

---

របាយការណ៍នេះរៀបចំដោយ
មជ្ឈមណ្ឌលទីផ្សារ និងទំនាក់ទំនង និងគណៈកម្មាធិការប្រតិបត្តិ វិទ្យាស្ថាន ពាណិជ្ជសាស្ត្រ អេស៊ីលីដា
និងចេញផ្សាយដោយ មជ្ឈមណ្ឌលទីផ្សារ និងទំនាក់ទំនង ។

សម្រាប់ព័ត៌មានបន្ថែម និងចម្ងល់ផ្សេងៗ
សូមទាក់ទងមក វិទ្យាស្ថាន ពាណិជ្ជសាស្ត្រ អេស៊ីលីដា អាសយដ្ឋាន៖
អគារលេខ១៣៩៧ មហាវិថីមិត្តភាព ភ្នំពេញ-ហាណូយ ភូមិអន្លង់ក្ងាន សង្កាត់ឃ្មួញ
ខណ្ឌសែនសុខ រាជធានីភ្នំពេញ ព្រះរាជាណាចក្រកម្ពុជា ។

ប្រអប់សំបុត្រលេខ ៖ ១១៤៩
០២៣ ៩៩៩ ៩៤៤ / ៩៨៦ ៩៣៧
info@acleda-aib.edu.kh
www.acleda-aib.edu.kh
ACLEDA INSTITUTE OF BUSINESS



# កម្មវិធីអប់រំ និងបណ្ដុះបណ្ដាលរបស់ វិទ្យាស្ថាន ពាណិជ្ជសាស្ត្រ អេស៊ីលីដា

## កម្មវិធីអប់រំកម្រិតឧត្តមសិក្សា

វិទ្យាស្ថាន ពាណិជ្ជសាស្ត្រ អេស៊ីលីដា បានបំពេញមុខងារដ៏សំខាន់ក្នុងការអប់រំកម្រិតឧត្តមសិក្សា ឯកទេស គ្រប់គ្រងពាណិជ្ជកម្ម ជំនាញហិរញ្ញវត្ថុ និងធនាគារ ប្រកបដោយគុណភាព និងសីលធម៌ ជូនដល់និស្សិត ។



១- ថ្នាក់បរិញ្ញាបត្រ




២- ថ្នាក់បរិញ្ញាបត្ររង

## កម្មវិធីបណ្តុះបណ្តាលសម្រាប់ស្ថាប័នខាងក្រៅ និងសាធារណជន

វិទ្យាស្ថាន ពាណិជ្ជសាស្ត្រ អេស៊ីលីដា ផ្តល់នូវការហ្វឹកហ្វឺនផ្សេងៗពីគ្នា ដែលគួបផ្សំចំណេះដឹង និងជំនាញ ក្នុងការអនុវត្តការងារដោយផ្តោតលើគុណភាពជាចម្បង ។ បច្ចុប្បន្ននេះ វិទ្យាស្ថាន ពាណិជ្ជសាស្ត្រ អេស៊ីលីដា មានកម្មវិធីហ្វឹកហ្វឺន៨ប្រភេទ ផ្តល់ជូនអតិថិជនមកពីស្ថាប័នខាងក្រៅ ទាំងក្នុងប្រទេស និងអន្តរជាតិ ៖



១- វគ្គហ្វឹកហ្វឺនតាមប្រតិទិនហ្វឹកហ្វឺនប្រចាំឆ្នាំ



២- វគ្គហ្វឹកហ្វឺនតាមតម្រូវការ ឬតាមការស្នើសុំ



៣- វគ្គទស្សនកិច្ចសិក្សា សម្រាប់ប្រតិបត្តិករមីក្រូហិរញ្ញវត្ថុ




៤- វគ្គសិក្ខាសាលា និងទស្សនកិច្ចសិក្សាផ្លាស់ប្តូរបទពិសោធន៍
សម្រាប់និយតករមីក្រូហិរញ្ញវត្ថុ



៥- វគ្គហ្វឹកហ្វឺនអភិវឌ្ឍន៍ជំនាញ សម្រាប់និស្សិត និងសាធារណជន



៦- វគ្គហ្វឹកហាត់ការងារជាក់ស្តែងនៅកន្លែងការងារ



៧- វគ្គសិក្សាភាសាអង់គ្លេសទូទៅ



៨- វគ្គសិក្សាភាសាអង់គ្លេសសម្រាប់គោលបំណងជាក់លាក់

# កម្មវិធីបណ្តុះបណ្តាលសម្រាប់កម្មករនិយោជិត ធនាគារ អេស៊ីលីដា ភីអិលស៊ី

វិទ្យាស្ថាន ពាណិជ្ជសាស្ត្រ អេស៊ីលីដា បានបំពេញមុខងារដ៏សំខាន់ផងដែរក្នុងការបណ្តុះបណ្តាលសមត្ថភាពកម្មករនិយោជិត ដែលបានរួមចំណែកនៅក្នុងភាពជោគជ័យរបស់ ធនាគារ អេស៊ីលីដា ភីអិលស៊ី ។ បច្ចុប្បន្ននេះ វិទ្យាស្ថាន ពាណិជ្ជសាស្ត្រ អេស៊ីលីដា មានកម្មវិធីហ្វឹកហ្វឺន ៤ ប្រភេទ សម្រាប់បណ្តុះបណ្តាលកម្មករនិយោជិត ធនាគារ អេស៊ីលីដា ភីអិលស៊ី ៖



១- វគ្គហ្វឹកហ្វឺនកម្មករនិយោជិតថ្មី




២- វគ្គហ្វឹកហ្វឺនការងារដំបូង



៣- វគ្គបណ្តុះបណ្តាលអភិវឌ្ឍន៍ជំនាញ



៤- វគ្គសិក្ខាសាលាបណ្តុះបណ្តាលគ្រូហ្វឹកហ្វឺន

# វិវឌ្ឍនាការ របស់វិទ្យាស្ថាន ពាណិជ្ជសាស្ត្រ អេស៊ីលីដា

បន្ទាប់ពីកម្លាយខ្លួនជាវិទ្យាស្ថាន ពាណិជ្ជសាស្ត្រ អេស៊ីលីដា នៅថ្ងៃទី២៤ ខែមករា ឆ្នាំ២០១៦ វិទ្យាស្ថានបានពង្រីកវិសាលភាពរបស់ខ្លួនតាមរយៈការវិនិយោគសាងសង់អគារវិទ្យាស្ថានថ្មីផ្ទាល់ខ្លួន កម្រិតបទដ្ឋានអន្តរជាតិលើផ្ទៃដីជាង ៧.៥ ហិចតា ក្នុងទំហំទឹកប្រាក់រហូតដល់ ៣៩.៦៦៩.០៧៤ ដុល្លារអាមេរិក។ ការវិវឌ្ឍនេះបានឆ្លុះបញ្ចាំងពីការប្ដេជ្ញាចិត្តខ្ពស់ ក្នុងការវិនិយោគលើវិស័យអប់រំរយៈពេលយូរអង្វែង និងបានកំណត់នូវគុណតម្លៃ និងទស្សនវិជ្ជារបស់ខ្លួនគឺ គុណភាព ក្រមសីលធម៌ ការងារ និង វិជ្ជាជីវៈ។ គិតមកដល់ចុងឆ្នាំ២០១៧ អគារវិទ្យាស្ថានថ្មី បានសម្រេចលទ្ធផលសាងសង់ ៤០.៧% នឹងមានគម្រោងដាក់ឲ្យប្រើប្រាស់ជាផ្លូវការនៅត្រីមាសទី៤ ឆ្នាំ២០១៨ ខាងមុខ។












វិទ្យាស្ថាន ពាណិជ្ជសាស្ត្រ អេស៊ីលីដា បញ្ចុះបឋមសិលាសាងសង់អគារវិទ្យាស្ថានផ្ទាល់ខ្លួន ស្ថិតនៅភូមិអន្លង់ក្ងាន សង្កាត់ឃ្មួញ ខណ្ឌសែនសុខ រាជធានីភ្នំពេញ

ដើម្បីអភិវឌ្ឍគុណភាពអប់រំឲ្យកាន់តែល្អប្រសើរ និងតាមរយៈការប្រឹក្សាយោបល់ពីអ្នកឯកទេសជាន់ខ្ពស់លើវិស័យសិក្សាអប់រំ របស់សាជីវកម្មហិរញ្ញវត្ថុអន្តរជាតិ(IFC) វិទ្យាស្ថាន ពាណិជ្ជសាស្ត្រ អេស៊ីលីដា បានសហការជាមួយ William Davidson Institute នៃ University of Michigan សហរដ្ឋអាមេរិក ក្នុងការសិក្សា និងវាយតម្លៃអំពីលទ្ធផលប្រតិបត្តិការ ដើម្បីផ្តល់អនុសាសន៍លើយុទ្ធសាស្ត្រដែលអាចធ្វើឲ្យ វិទ្យាស្ថាន ពាណិជ្ជសាស្ត្រ អេស៊ីលីដា សម្រេចបាននូវចក្ខុវិស័យ ជាថ្នាលអប់រំធុរៈកិច្ចប្រកបដោយគុណភាពឈានមុខ រួមចំណែកអភិវឌ្ឍសេដ្ឋកិច្ចកម្ពុជា និងតំបន់។ ជាដំណាក់កាលបន្ទាប់ នាយកវិទ្យាស្ថាន បានដឹកនាំគណៈប្រតិភូធ្វើទស្សនកិច្ចសិក្សាដោយផ្ទាល់នៅ Ross School of Business(RSB) នៃ University of Michigan ដើម្បីបង្កើតទស្សនវិស័យស្តីពីរបៀបដែលសាលាធុរកិច្ច លំដាប់ថ្នាក់ពិភពលោកកំពុងធ្វើប្រតិបត្តិការ សង្កេតលើយុទ្ធសាស្ត្រជាចំបង និងការអនុវត្តយុទ្ធសាស្ត្ររបស់ RSB និងដកស្រង់បទពិសោធន៍ល្អៗ ដែលមានគុណប្រយោជន៍សម្រាប់យកមកអភិវឌ្ឍ វិទ្យាស្ថាន ពាណិជ្ជសាស្ត្រ អេស៊ីលីដា ។










នាយកវិទ្យាស្ថាន ដឹកនាំគណៈប្រតិភូធ្វើទស្សនកិច្ចសិក្សាដោយផ្ទាល់នៅ Ross School of Business(RSB) នៃ University of Michigan

# សមិទ្ធផលការអប់រំសិក្សា និងបណ្តុះបណ្តាល

ក- និស្សិតថ្នាក់ឧត្តមសិក្សា

| ប្រភេទនិស្សិត | ២០១៦-២០១៦ | ២០១៦-២០១៧ |
|---|---|---|
| និស្សិតថ្នាក់បរិញ្ញាបត្រ | ៣២២ | ៤៨៨ |
| និស្សិតថ្នាក់បរិញ្ញាបត្ររង | ៨៨ | ១៤២ |
| **និស្សិតសរុប** | ៤១០ | ៦៣០ |






សកម្មភាពអប់រំបណ្តុះឆន្ទៈដើម្បីភាពជោគជ័យក្នុងការសិក្សា ដល់និស្សិតវិទ្យាស្ថាន ពាណិជ្ជសាស្ត្រ អេស៊ីលីដា

## ខ - សិក្ខាកាមជាកម្មករនិយោជិត ធនាគារ អេស៊ីលីដា ភីអិលស៊ី

| ប្រភេទវគ្គហ្វឹកហ្វឺន | ២០០៤-២០០៩ | ២០០៤-២០១០ | ២០០៤-២០១១ | ២០០៤-២០១២ | ២០០៤-២០១៣ | ២០០៤-២០១៤ | ២០០៤-២០១៥ | ២០០៤-២០១៦ | ២០០៤-២០១៧ |
|---|---|---|---|---|---|---|---|---|---|
| វគ្គហ្វឹកហ្វឺនកម្មករនិយោជិតថ្មី | ៦.៨២១ | ៧.១៦០ | ៧.៩៥៦ | ៩.៣៣២ | ១២.០៤៣ | ១៤.៤១១ | ១៦.១២៨ | ១៧.៤៣៥ | ១៨.៦១៤ |
| វគ្គហ្វឹកហ្វឺនអភិវឌ្ឍន៍ជំនាញ | ១១៧.២៥២ | ១៦០.១៨៦ | ១៩៤.៥៧១ | ២២៦.៦៦១ | ២៦៧.៤៧០ | ៣០៨.៣៧៩ | ៣៤៦.០៩០ | ៣៩០.៥៦៦ | ៤៥៣.៧៤២ |
| វគ្គហ្វឹកហ្វឺនការងារដំបូង | ៣.៤៣៥ | ៤.២៣៨ | ៥.១៦២ | ៦.៥៤០ | ៨.៣៤២ | ១០.១៩៨ | ១១.៨៦៥ | ១៣.៣៤៥ | ១៤.៥៨៧ |
| **សិក្ខាកាមសរុប** | ១២៧.៥០៨ | ១៧១.៥៨៤ | ២០៧.៦៨៩ | ២៤២.៥៣៣ | ២៨៧.៨៥៥ | ៣៣២.៩៨៨ | ៣៧៤.០៨៣ | ៤២១.៣៤៦ | ៤៨៦.៩៤៣ |



គ- សិក្ខាកាមមកពីស្ថាប័នខាងក្រៅ និងជានិស្សិត

| ប្រភេទសិក្ខាកាម | ២០០៤-២០០៩ | ២០០៤-២០១០ | ២០០៤-២០១១ | ២០០៤-២០១២ | ២០០៤-២០១៣ | ២០០៤-២០១៤ | ២០០៤-២០១៥ | ២០០៤-២០១៦ | ២០០៤-២០១៧ |
|---|---|---|---|---|---|---|---|---|---|
| សិក្ខាកាមក្នុងប្រទេស | ៣០៥ | ៦១៧ | ៨៤៧ | ១.១១៥ | ១.៧៥០ | ២.៨៧១ | ៤.១៨៦ | ៤.៩៦៨ | ៥.៧២៦ |
| សិក្ខាកាមអន្តរជាតិ | ២៩៨ | ៥១៧ | ៧១៧ | ៨៦៨ | ១.៣០៣ | ១.៥៥៨ | ១.៧១៦ | ១.៧៩៦ | ១.៨៦២ |
| **សិក្ខាកាមសរុប** | **៦០៣** | **១.១៣៤** | **១.៥៦៤** | **១.៩៨៣** | **៣.០៥៣** | **៤.៤២៩** | **៥.៩០២** | **៦.៧៦៤** | **៧.៥៨៨** |



# ទិន្នន័យហិរញ្ញវត្ថុសង្ខេប

| ឯកតាគិតជាដុល្លារអាមេរិក | ៣១/១២/១៧ បានធ្វើសវនកម្ម | ៣១/១២/១៦ បានធ្វើសវនកម្ម | ៣១/១២/១៥ បានធ្វើសវនកម្ម | បម្រែបម្រួល (%)[១] |
|---|---|---|---|---|
| **ទិន្នន័យហិរញ្ញវត្ថុសង្ខេប** | | | | |
| ទ្រព្យសកម្ម | ២៧.៦៤៩.១៣១ | ២៦.៦០៥.៩៤៩ | ១៦.៧៦៧.៦៩៤ | ៣,៩២% |
| បំណុល | ៦.៦២៤.៥០៧ | ៥.៧៤២.៩៥៧ | ៧០១.២៩៩ | ១៥,៣៥% |
| ដើមទុន | ១៧.៨០៥.000 | ១៧.៨០៥.000 | ១២.៨០៥.000 | 0% |
| មូលនិធិម្ចាស់ហ៊ុន | ២១.០២៤.៦២៤ | ២០.៨៦២.៩៩២ | ១៦.០៦៦.៣៩៥ | 0,៧៧% |
| ចំណូលដុល | ២.៦១១.៩៦៩ | ២.00៦.៧៣៥ | ២.៣៧៥.៨៦២ | ៣0,១៦% |
| ប្រាក់ចំណេញមុនដកពន្ធ | ១៤0.0៨៨ | (២២៦.២៤៥) | ៣៥៩.១៥៩ | ១៦១,៩២% |
| ប្រាក់ចំណេញសុទ្ធក្រោយដកពន្ធ | ១៦១.៦៣២ | (២0៣.៤0៣) | ២៨៧.00៩ | ១៧៩,៤៦% |
| ចំណេញក្នុងមួយភាគហ៊ុន | $0,00៩ | $0,00 | $0,0២ | 0% |
| ភាគលាភ [២] | $0,00 | $0,00 | $0,00 | 0% |

១ គិតពីថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០១៦ ដល់ថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០១៧

២ ភាគលាភ មិនត្រូវបានបែងចែកពីប្រាក់ចំណេញសុទ្ធក្រោយដកពន្ធ (ធនាគារ អេស៊ីលីដា ភីអិលស៊ី, ក្រុមហ៊ុនមេ, កាន់កាប់ភាគហ៊ុន វិទ្យាស្ថាន ពាណិជ្ជសាស្ត្រ អេស៊ីលីដា ១០០%)



កិច្ចប្រជុំក្រុមប្រឹក្សាភិបាល វិទ្យាស្ថាន ពាណិជ្ជសាស្ត្រ អេស៊ីលីដា



កិច្ចប្រជុំគណៈកម្មាធិការប្រតិបត្តិ នៃវិទ្យាស្ថាន ពាណិជ្ជសាស្ត្រ អេស៊ីលីដា

# ចំណុចសំខាន់ៗក្នុងឆ្នាំ២០១៧

- ទ្រព្យសកម្មកើនឡើង ៣,៩២% រហូតដល់ ២៧,៦៤៩,១៣១ដុល្លារអាមេរិក
- ប្រាក់ចំណេញសុទ្ធក្រោយដកពន្ធកើនឡើង ១៧៩,៤៦% រហូតដល់ ១៦១,៦៣២ ដុល្លារអាមេរិក
- មូលនិធិម្ចាស់ហ៊ុនកើនឡើង ០,៧៧% រហូតដល់ ២១,០២៤,៦២៤ ដុល្លារអាមេរិក
- បានបណ្តុះបណ្តាលកម្មករនិយោជិត ធនាគារ អេស៊ីលីដា ភីអិលស៊ី ចំនួន ៦.១៧៦វគ្គ មានសិក្ខាកាមចូលរួមសរុប ចំនួន ៦៥.៥៩៧នាក់
- បានបណ្តុះបណ្តាលកម្មករនិយោជិតក្រុមហ៊ុនបុត្រសម្ព័ន្ធក្រៅប្រទេសចំនួន ២វគ្គ មានសិក្ខាកាមចូលរួមសរុប ចំនួន ៩នាក់
- បានបណ្តុះបណ្តាល និងចែករំលែកបទពិសោធន៍សម្រាប់ស្ថាប័នខាងក្រៅចំនួន ៣៣វគ្គ មានសិក្ខាកាមចូលរួមសរុបចំនួន ៧៣២នាក់
- បានបើកវគ្គបណ្តុះបណ្តាលអភិវឌ្ឍន៍ជំនាញសម្រាប់និស្សិតចំនួន ៧វគ្គ មានសិក្ខាកាមចូលរួមសរុប ៨៣នាក់
- បានបើកវគ្គបណ្តុះបណ្តាលថ្នាក់ភាសាអង់គ្លេសកម្រិតទូទៅ សម្រាប់កម្មករនិយោជិត ធនាគារ អេស៊ីលីដា ភីអិលស៊ី និងសាធារណជនទូទៅ ចំនួន ៤០ថ្នាក់ មានសិក្ខាកាមចូលរួមសរុប ៤២៨នាក់ ។
- បានបើកថ្នាក់ឧត្តមសិក្សា (បរិញ្ញាបត្រ និងបរិញ្ញាបត្ររង) ចំនួន ២៨ថ្នាក់ មាននិស្សិតសរុប ៦៣០នាក់ ។








និស្សិតវិទ្យាស្ថាន ពាណិជ្ជសាស្ត្រ អេស៊ីលីដា ចូលរួមស្តាប់បឋកថា របស់ បណ្ឌិត អ៊ិន ចាន់នី ប្រធាននាយកប្រតិបត្តិធនាគារ អេស៊ីលីដា ភីអិលស៊ី

# លទ្ធផលដែលបានអនុវត្ត

## ទ្រព្យសកម្មសរុប/មូលនិធិម្ចាស់ហ៊ុន និងផលលើមូលធន




## ចំនួនសិក្ខាកាម



# មាតិកា


របាយការណ៍ប្រធានក្រុមប្រឹក្សាភិបាល ....... ១៤

របាយការណ៍នាយកវិទ្យាស្ថាន ....... ១៧

អង្គការលេខ ....... ២០

ភាគទុនិក ....... ២១

ក្រុមប្រឹក្សាភិបាល ....... ២២

គណៈកម្មាធិការប្រតិបត្តិ ....... ២៥

ទីប្រឹក្សា ....... ២៨

ក្រុមសីលធម៌ ....... ២៩

ការិយាល័យកណ្តាល ធនាគារ អេស៊ីលីដា ភីអិលស៊ី និងបុគ្គលសម្ព័ន្ធ ....... ៣០

សកម្មភាពអប់រំបណ្តុះបណ្តាល ....... ៣១




វិទ្យាស្ថាន ពាណិជ្ជសាស្ត្រ អេស៊ីលីដា និង សាលាសេនត្រល់ផាក-កម្ពុជា ចុះហត្ថលេខាលើអនុស្សរណៈយោគយល់គ្នា
ស្តីពីកិច្ចសហប្រតិបត្តិការលើការផ្សព្វផ្សាយសេវាអប់រំ និងផ្តល់អត្ថប្រយោជន៍ដល់សិស្សនិស្សិត



ប្រតិភូ Ross School of Business(RSB) នៃ University of Michigan សិក្សាស្វែងយល់ពីប្រតិបត្តិការរបស់វិទ្យាស្ថាន ពាណិជ្ជសាស្ត្រ អេស៊ីលីដា

# របាយការណ៍ប្រធានក្រុមប្រឹក្សាភិបាល



## បណ្ឌិត សូ ផនណារី

ប្រធានក្រុមប្រឹក្សាភិបាល

ជាមួយនឹងភាពរីកចម្រើនគួរឲ្យកត់សម្គាល់ នៃវិស័យអប់រំនៅក្នុងប្រទេសកម្ពុជា ការបណ្តុះវប្បធម៌សិក្សារៀនសូត្រពេញមួយជីវិត និងការចែករំលែកបទពិសោធន៍ជាមួយបណ្តាញផ្តល់សេវាអប់រំ និងវិជ្ជាជីវៈ ទាំងនៅក្នុង និងក្រៅប្រទេស និងការបង្កើនគុណវឌ្ឍិសាស្ត្រាចារ្យ នូវចំណេះដឹងមុខវិជ្ជាឯកទេស ក្រមសីលធម៌វិជ្ជាជីវៈគរុកោសល្យ និងការលើកទឹកចិត្ត ជាពិសេសការពង្រឹងអភិបាលកិច្ច គឺជាយុទ្ធសាស្ត្រដែលបាននិងកំពុងបន្តអនុវត្ត ដោយឈរលើមូលដ្ឋាននៃចក្ខុវិស័យ និងបេសកកម្មរបស់វិទ្យាស្ថាន ពាណិជ្ជសាស្ត្រ អេស៊ីលីដា ។ ម្យ៉ាងវិញទៀត ប្រទេសកម្ពុជាស្ថិតនៅក្នុងចំណោមបណ្តាប្រទេសដែលមានសេដ្ឋកិច្ចរីកលូតលាស់ខ្ពស់ជារៀងរាល់ឆ្នាំ ដែលជំរុញឲ្យវិទ្យាស្ថាន ពាណិជ្ជសាស្ត្រ អេស៊ីលីដា មានការប្តេជ្ញាចិត្តខ្ពស់ក្នុងការបំពេញធុរកិច្ច រួមចំណែកយ៉ាងសកម្ម ក្នុងការបណ្តុះបណ្តាលធនធានមនុស្សឲ្យមានគ្រប់គ្រាន់ ប្រកបដោយគុណភាព ដើម្បីឆ្លើយតបទៅនឹងតម្រូវការជាក់ស្តែងនៅក្នុងប្រទេស និងក្នុងតំបន់ ។

## វិស័យអប់រំកម្ពុជាក្នុងឆ្នាំ២០១៧

ដើម្បីឆ្លើយតបទៅនឹងបំណងប្រាថ្នារបស់កម្ពុជា ក្នុងការសម្រេចបាននូវស្ថានភាពប្រទេសមានប្រាក់ចំណូលមធ្យមកម្រិតខ្ពស់ នៅត្រឹមឆ្នាំ២០៣០ ការដោះស្រាយបញ្ហាធនធានមនុស្សខុសជំនាញ និងការធ្វើពិពិធកម្មនៃកំណើនឧស្សាហកម្ម ក្រសួងអប់រំ យុវជន និងកីឡា បានចាប់ផ្តើមធ្វើកំណែទម្រង់វិស័យអប់រំ ដើម្បីផ្តល់ការអប់រំ ប្រកបដោយគុណភាព និងមូលដ្ឋានគ្រឹះជំនាញដល់យុវវ័យ ដើម្បីឲ្យពួកគេអាចចាប់យកអនាគត ។ រាជរដ្ឋាភិបាលកម្ពុជា មានបំណងចង់ឲ្យយុវជនជំនាន់ក្រោយ មានលក្ខណៈសម្បត្តិល្អ ទទួលបាននូវចំណេះដឹង ជំនាញទន់ និងបំណិនជីវិត ការប្តេជ្ញាចិត្តក្នុងការអភិវឌ្ឍសហគមន៍ និងការអភិវឌ្ឍប្រកបដោយចីរភាព ។

ក្នុងឆ្នាំ២០១៥ បន្ទាប់ពីបានធ្វើកំណែទម្រង់ ការប្រឡងសញ្ញាបត្រមធ្យមសិក្សាទុតិយភូមិ លើកទី១មក ក្រសួងអប់រំ យុវជន និងកីឡា បានដាក់ចេញនូវចក្ខុវិស័យ កំណែទម្រង់អប់រំដែលឈរលើសសរស្តម្ភ ៥ រួមមាន៖

១- ការអនុវត្តផែនការសកម្មភាពគោលនយោបាយគ្រូបង្រៀន
២- អធិការកិច្ចសាលារៀន
៣- ការវាយតម្លៃការសិក្សារបស់សិស្ស
៤- ការពិនិត្យឡើងវិញកម្មវិធីសិក្សានិង
៥- កំណែទម្រង់ឧត្តមសិក្សា

កំណែទម្រង់នៅក្នុងអនុវិស័យអប់រំឧត្តមសិក្សារួមមាន៖

១)-ធានាឱ្យការអប់រំ មានគុណភាពប្រកបដោយសមធម៌ បរិយាបន្ន និងលើកកម្ពស់ឱកាសសិក្សាពេញមួយជីវិត សម្រាប់ទាំងអស់គ្នាតាមរយៈការពង្រឹងយន្តការជ្រើសរើសនិស្សិត ការរៀបចំក្របខណ្ឌគោលនយោបាយឧត្តមសិក្សា ការធានាគុណភាពអប់រំនៅឧត្តមសិក្សា និងការលើកកម្ពស់ការបង្រៀន និងការស្រាវជ្រាវ ។

២)-ធានាភាពស័ក្តិសិទ្ធិនៃភាពជាអ្នកដឹកនាំ និងគ្រប់គ្រងរបស់មន្ត្រីអប់រំគ្រប់លំដាប់ថ្នាក់ តាមរយៈការលើកកម្ពស់ អភិបាលកិច្ចគ្រឹះស្ថានឧត្តមសិក្សា និងការអភិវឌ្ឍសមត្ថភាពមន្ត្រីឧត្តមសិក្សា ។

ក្រសួងអប់រំ យុវជន និងកីឡា បានឈានដល់ដំណាក់កាលបញ្ចប់អាណត្តិ នៃការអនុវត្តផែនការយុទ្ធសាស្ត្រ វិស័យអប់រំ ២០១៤-២០១៨ ស្របតាមផែនការអភិវឌ្ឍន៍ជាតិ ២០១៤-២០១៨ របស់រាជរដ្ឋាភិបាលនីតិកាលទី៥នៃរដ្ឋសភា ។ គោលនយោបាយយុទ្ធសាស្ត្រកម្មវិធី និងចង្កោមសកម្មភាពជាអាទិភាពរបស់ក្រសួងអប់រំ យុវជន និងកីឡា ត្រូវបានសម្រេចដើម្បីឈានទៅអនុវត្តគោលដៅអភិវឌ្ឍន៍ប្រកបដោយចីរភាពឆ្នាំ២០៣០ ។

គិតមកដល់ដំណាច់ឆ្នាំ២០១៧ នៅទូទាំងប្រទេសកម្ពុជា មានគ្រឹះស្ថានឧត្តមសិក្សា ចំនួន១២១ នៅក្នុងនោះគ្រឹះស្ថាន ឧ ត្តមសិក្សារដ្ឋ មានចំនួន ៤៨ និងឯកជន មានចំនួន ៧៣ ដែលមានទីតាំ ង នៅក្នុង២០ខេត្ត និងរាជធានីភ្នំពេញ ។ គ្រឹះស្ថានឧត្ត ម សិក្សាស្ថិតក្រោមការគ្រប់គ្រងរបស់ក្រសួងស្ថាប័ន១៦ ។ គ្រឹះ ស្ថានឧត្តមសិក្សាដែលស្ថិតក្រោមការគ្រប់គ្រងរបស់ក្រសួងអប់រំ យុវជន និងកីឡា មានចំនួន៧៣ (រដ្ឋ១៣ និងឯកជន៦០)។ គ្រឹះស្ថានឧត្តមសិក្សា៣៨ ផ្តល់សេវាអប់រំថ្នាក់ក្រោយបរិញ្ញាបត្រ ។

គ្រូបង្រៀនអប់រំឧត្តមសិក្សាមានចំនួន១៤.៩៦០នាក់ (ស្រី១៨,៦៣%) ក្នុងនោះគ្រូមានសញ្ញាបត្រកម្រិតបរិញ្ញាបត្រ ចំនួន៤.៨៧៧នាក់ ស្មើនឹង ៣២,៦០% (ស្រី១.៦១៥នាក់ ស្មើនឹង៣៣,១១%) កម្រិតបរិញ្ញាបត្រជាន់ខ្ពស់ ចំនួន ៨. ៨០៥នាក់ ស្មើនឹង ៥៨,៨៥% (ស្រី១.០៦១នាក់ ស្មើនឹង១២,០៥%) និងកម្រិតបណ្ឌិត ចំនួន១.២៧៨នាក់ ស្មើនឹង ៨,៥៤% (ស្រី១១២នាក់ ស្មើនឹង៨,៧៦%) ។

និស្សិតកំពុងសិក្សានៅគ្រឹះស្ថានឧត្តមសិក្សា ចាប់ពីថ្នាក់បរិញ្ញាបត្ររងដល់ថ្នាក់បណ្ឌិត មានចំនួនសរុប ២០៧.៤៣៤នាក់ (ស្រី៤៨,៣៧%) ដែលក្នុងនោះនិស្សិតបរទេស មានចំនួន១៧៣នាក់ (ស្រី៦៧នាក់ ស្មើនឹង ៣៨,៧៣%) រួមមាននិស្សិតអាហារូបករណ៍ ចំនួន ១៦១នាក់ (ស្រី៦០នាក់ ស្មើនឹង៣៧,២៧%) ។ និស្សិតកំពុងសិក្សាថ្នាក់បរិញ្ញាបត្ររង មានចំនួន ២០.៥៧០នាក់ (ស្រី៥១,០៦%) ថ្នាក់បរិញ្ញាបត្រ មាននិស្សិតកំពុងសិក្សា ចំនួន ១៦៥.៣៥៩នាក់ (ស្រី៤៧,៨៧%) ថ្នាក់បរិញ្ញាបត្រជាន់ខ្ពស់ មាននិស្សិតកំពុងសិក្សា ចំនួន ២០.២៧២នាក់ (ស្រី២២,២១%) និងថ្នាក់បណ្ឌិត មាននិស្សិតកំពុងសិក្សា ចំនួន ១.២២២នាក់ (ស្រី៥,១៦%) ។

## លទ្ធផលសម្រេចបានរបស់ វិទ្យាស្ថាន ពាណិជ្ជសាស្ត្រ អេស៊ីលីដា ក្នុងឆ្នាំ២០១៧

ក្រុមប្រឹក្សាភិបាល មានទំនួលខុសត្រូវលើការកំណត់យុទ្ធសាស្ត្រ និងដឹកនាំត្រួតពិនិត្យដំណើការអាជីវកម្មរបស់ វិទ្យាស្ថាន ពាណិជ្ជសាស្ត្រ អេស៊ីលីដា ដើម្បីធានាបាននូវអភិបាលកិច្ចសាជីវកម្ម និងការបង្កើនអត្ថប្រយោជន៍ជូនដល់ភាគទុនិក កម្មករនិយោជិត និងសហគមន៍ទាំងអស់ ។ ក្រុមប្រឹក្សាភិបាល បានផ្តល់នូវគំនិតថ្មីៗ គាំទ្រ និងលើកទឹកចិត្តដល់ការប្រកាន់ខ្ជាប់នូវគោលការណ៍អភិបាលកិច្ចល្អ សីលធម៌វិជ្ជាជីវៈសង្គម ច្បាប់ និងបរិស្ថាន ប្រកបដោយកម្រិតខ្ពស់បំផុត ។

ដើម្បីធានាបាននូវនិរន្តរភាពនៃប្រតិបត្តិការរបស់ វិទ្យាស្ថាន ពាណិជ្ជសាស្ត្រ អេស៊ីលីដា អង្គប្រជុំក្រុមប្រឹក្សាភិបាល (ជួបប្រជុំផ្ទាល់) ត្រូវបានរៀបចំឡើងជាទៀងទាត់ចំនួនបួនដងក្នុងមួយឆ្នាំ និងអង្គប្រជុំវិសាមញ្ញក្រុមប្រឹក្សាភិបាល មួយចំនួនទៀត អាចធ្វើឡើងនៅពេលមានសំណូមពរ ពីសមាជិកក្រុម-ប្រឹក្សាភិបាលចំនួនមួយភាគបី ដែលអង្គប្រជុំអាចរៀបចំ ឡើងជាលក្ខណៈជួបប្រជុំផ្ទាល់ ឬតាមមធ្យោបាយអេឡិចត្រូនិច ឬទូរសព្ទ ។

## សកម្មភាពសំខាន់ៗរបស់ក្រុមប្រឹក្សាភិបាល ក្នុងឆ្នាំ២០១៧រួមមាន៖

- បានត្រួតពិនិត្យលើរបាយការណ៍ហិរញ្ញវត្ថុ និងរបាយការណ៍វឌ្ឍនភាពនៃប្រតិបត្តិការអាជីវកម្មប្រចាំខែ ប្រចាំត្រីមាស ព្រមទាំងបានផ្តល់អនុសាសន៍ និងផែនការសកម្មភាពការងារដល់ថ្នាក់ដឹកនាំជាន់ខ្ពស់ របស់វិទ្យាស្ថាន ពាណិជ្ជសាស្ត្រ អេស៊ីលីដា ដើម្បីជំរុញដំណើការអាជីវកម្មឱ្យទទួលលទ្ធផលកាន់តែប្រសើរឡើង ។
- បានអនុម័តលើស្លាកសញ្ញា និងត្រាថ្មីរបស់ វិទ្យាស្ថាន ពាណិជ្ជសាស្ត្រ អេស៊ីលីដា។
- បានអនុម័តលើការតែងតាំង បណ្ឌិត អ៊ុង សំអ៊ុល ជាសមាជិកក្រុមប្រឹក្សាភិបាល ជាតំណាងសាស្ត្រាចារ្យ និងបុគ្គលិក និងជាសមាជិកគណៈកម្មាធិការសិក្សាធិការនៃក្រុមប្រឹក្សាភិបាល ។
- បានអនុម័តយល់ព្រមលើលក្ខន្តិកៈរបស់គណៈកម្មាធិការសិក្សាធិការ នៃក្រុមប្រឹក្សាភិបាល ។
- បានអនុម័តលើលក្ខខណ្ឌផ្តល់ប្រាក់រង្វាន់លើកទឹកចិត្ត ក្នុងភាគកម្មប្រាក់ចំណេញសម្រាប់នាយកវិទ្យាស្ថាន ពាណិជ្ជសាស្ត្រ អេស៊ីលីដា ។
- បានអនុម័តយល់ព្រមលើ គោលកាណ៍អភិបាលកិច្ចសាជីវកម្ម និងគោលកាណ៍ទំនាស់ផលប្រយោជន៍ ។
- បានអនុម័តយល់ព្រមលើអត្រាអតិផរណាសម្រាប់វិទ្យាស្ថាន ពាណិជ្ជសាស្ត្រ អេស៊ីលីដាស្មើនឹង២,៩% ។
- បានអនុម័តលើផែនការអាជីវកម្មឆ្នាំ២០១៨-២០២២ដំណាក់កាលទី២ ។
- បានអនុម័តលើលិខិតលាឈប់ពីសមាជិកក្រុមប្រឹក្សាភិបាលរបស់លោក បណ្ឌិត ឌី សមស៊ីដេត ។



រូបថតអនុស្សាវរីយ ឯកឧត្តមបណ្ឌិត ហង់ ជួន ណារ៉ុន រដ្ឋមន្ត្រីក្រសួងអប់រំ យុវជន និងកីឡា ជាមួយ លោកស្រីបណ្ឌិត សូ ផនណារី ព្រមទាំងថ្នាក់ដឹកនាំរបស់ AIB

- បានអនុម័តតែងតាំង លោកបណ្ឌិត ឌី សមស៊ីដេត ជាប្រធានគណៈកម្មាធិការសិក្សាធិការនៃក្រុមប្រឹក្សាភិបាល ដែលគណៈកម្មាធិការនេះ គឺជាក្រុមប្រឹក្សាយោបល់របស់ក្រុមប្រឹក្សាភិបាល ។
- បានអនុម័តលើការកំណត់ពេលវេលា ដើម្បីត្រួតពិនិត្យឡើងវិញ នូវទស្សនវិស័យ បេសកកម្ម និងគោលដៅ របស់វិទ្យាស្ថាន ពាណិជ្ជសាស្ត្រ អេស៊ីលីដា ។
- បានអនុម័តជាគោលការណ៍លើសំណើសុំថវិកាចំណាយ លើគម្រោងប្រឹក្សាយោបល់ ពី William Davidson Institute (WDI) នៃសាកលវិទ្យាល័យ Michigan សម្រាប់គាំទ្រការអភិវឌ្ឍកម្មវិធីសិក្សារបស់វិទ្យាស្ថាន ពាណិជ្ជសាស្ត្រ អេស៊ីលីដា។
- បានអនុម័តផ្តល់សិទ្ធិអំណាចជូន នាយកវិទ្យាស្ថាន និងប្រធានក្រុមប្រឹក្សាភិបាល ជាសហហត្ថលេខីលើសញ្ញាប័ត្ររបស់និស្សិតវិទ្យាស្ថាន ពាណិជ្ជសាស្ត្រ អេស៊ីលីដា ។
- បានអនុម័តលើការផ្លាស់ប្តូរសមាជិកក្រុមប្រឹក្សាភិបាល និងតំណាងសាស្ត្រាចារ្យ របស់វិទ្យាស្ថាន ពាណិជ្ជសាស្ត្រ អេស៊ីលីដា ។
- បានអនុម័តគាំទ្រនិងលើកសំណើទៅភាគទុនិក សម្រាប់ការវិនិយោគជាមួយស្ថាប័នមីក្រូហិរញ្ញវត្ថុ អេស៊ីលីដា មីយ៉ាន់ម៉ា រហូតដល់១% ។
- បានអនុម័តយល់ព្រម និងផ្តល់អនុសាសន៍ជូនភាគទុនិក ដើម្បីស្នើសុំការយល់ព្រមវិនិយោគដើមទុនបន្ថែមចំនួន ២លានដុល្លារអាមេរិក និងកម្ចីសម្រាប់គម្រោងសាងសង់អាគារវិទ្យាស្ថាន ពាណិជ្ជសាស្ត្រ អេស៊ីលីដា ចំនួន៤លានដុល្លារអាមេរិក ក្នុងឆ្នាំ២០១៨ និង១លានដុល្លារអាមេរិក ក្នុងឆ្នាំ២០១៩ ។
- បានអនុម័តឲ្យប្រើប្រាស់អង្គការលេខថ្មី របស់វិទ្យាស្ថាន ពាណិជ្ជសាស្ត្រ អេស៊ីលីដា ជាទម្រង់ម៉ាទ្រិចព្រមទាំងមានការ៖ ១-ផ្លាស់ប្តូរឈ្មោះការិយាល័យទំនាក់ទំនងសាធារណៈ ជា ការិយាល័យទីផ្សារ និងទំនាក់ទំនង និង ២-ផ្លាស់ប្តូរមុខងារនាយករង និងជាប្រធានការិយាល័យផែនការ និងហិរញ្ញវត្ថុ ទៅជា នាយករង និងជាប្រធានហិរញ្ញវត្ថុ ។
- បានអនុម័តលើទស្សនវិស័យថ្មី របស់ វិទ្យាស្ថាន ពាណិជ្ជសាស្ត្រ អេស៊ីលីដា ។
- បានអនុម័តលើការតែងតាំង បណ្ឌិត ផុន ណារិន ជានាយកវិទ្យាស្ថាន ពាណិជ្ជសាស្ត្រ អេស៊ីលីដា ។
- បានអនុម័តលើការតែងតាំងនាយកស្តីទី នៃ វិទ្យាស្ថាន ពាណិជ្ជសាស្ត្រ អេស៊ីលីដា ជានាយករង និងជានាយកសិក្សាធិការ ។

សម្រាប់លទ្ធផលហិរញ្ញវត្ថុឆ្នាំ២០១៧ ដែលជាដំណាក់កាលដំបូងនៃប្រតិបត្តិការសេវាអប់រំឧត្តមសិក្សាវិទ្យាស្ថាន ពាណិជ្ជសាស្ត្រ អេស៊ីលីដា ទទួល បានចំណេញ ចំនួន ១៦១.៦៣២ដុល្លារអាមេរិក ខណៈទ្រព្យសកម្មសរុប បានកើនឡើង ៤% រហូតដល់ ២៧.៦៤៩.១៣១ដុល្លារអាមេរិក មូលនិធិម្ចាស់ហ៊ុនបានកើនឡើងចំនួន១% រហូតដល់២១.០២៤.៦២៤ដុល្លារអាមេរិក ។ អនុបាតប្រសិទ្ធភាពប្រតិបត្តិការបានថយចុះពី ៧២,៣៣% មកត្រឹម ៦០,៣៥% និងអត្រាប្រាក់ចំណូលដែលបានមកពីការហ្វឹកហ្វឺន និងបណ្តុះបណ្តាលសិក្ខាកាមមកពីខាងក្រៅ (ទាំងក្នុងនិងក្រៅប្រទេស) រួមនឹងចំណូលផ្សេងៗ ធៀបនឹងចំណូលដុលបានកើនឡើងពី ១៧,៣៦% រហូតដល់២២,៤៧% ។

## ផែនការយុទ្ធសាស្ត្រចម្បងៗសម្រាប់ឆ្នាំ២០១៨

ដើម្បីសម្រេចបានសមិទ្ធផលសម្រាប់ឆ្នាំ២០១៨ វិទ្យាស្ថាន ពាណិជ្ជសាស្ត្រ អេស៊ីលីដា បានកំណត់ផែនការជាអាទិភាពដូចតទៅ៖

- បន្តពង្រឹងលើការដឹកនាំត្រួតពិនិត្យដំណើការអាជីវកម្ម របស់ វិទ្យាស្ថាន ពាណិជ្ជសាស្ត្រ អេស៊ីលីដា ដើម្បីធានាបាននូវ អភិបាលកិច្ចសាជីវកម្មល្អ និងការបង្កើនអត្ថប្រយោជន៍ជូនដល់ភាគទុនិក កម្មករនិយោជិត និងសហគមន៍ទាំងអស់ ។
- បន្តពង្រឹងលើការប្រតិបត្តិគោលការណ៍ទាំងអស់ឱ្យបានខ្ជាប់ខ្ជួន និងជំរុញការអភិវឌ្ឍគោលការណ៍ប្រតិបត្តិ និងគ្រប់គ្រងកិច្ចការជំនួញ ឱ្យមានភាពត្រឹមត្រូវ គ្រប់គ្រាន់ និងទាន់សម័យស្របតាមការវិវឌ្ឍថ្មីៗ របស់ក្រុមហ៊ុនមេ និងទីផ្សារដោយធានាបាននូវអនុលោមភាពតាម ច្បាប់ជាតិ និងអន្តរជាតិ ជាពិសេសស្របទៅតាមផែនការកំណែទម្រង់ របស់ក្រសួងអប់រំ យុវជន និង កីឡា ដែលជាស្ថាប័នអាណាព្យាបាល ។
- លើកកម្ពស់ និងពង្រឹងវប្បធម៌ គុណភាព តម្លាភាព និងភាពមិនអត់ឱន ដោយអនុលោមតាមក្រុមហ៊ុនមេ និងដើម្បីក្លាយទៅជាស្ថាប័នគំរូនៅក្នុងវិស័យដែលខ្លួនកំពុងតែប្រតិបត្តិការ ។
- គណៈគ្រប់គ្រងក្រុមប្រឹក្សាភិបាល និងសាស្ត្រាចារ្យ ត្រូវធ្វើតាមស្តង់ដារខ្ពស់បំផុត នៃក្រមសីលធម៌សិក្សា ហើយនិស្សិតក៏ត្រូវបានតម្រូវឲ្យគោរពតាមក្រមសីលធម៌ផងដែរ ។
- បង្កើតបណ្តាញធំបំផុត ជាមួយសកលវិទ្យាល័យ ឬវិទ្យាស្ថានល្បីៗ ក្នុងតំបន់ ។
- ប្រែក្លាយបណ្ណាល័យ ឲ្យទៅជាធនធានល្អបំផុត និងជាមជ្ឈមណ្ឌលបណ្តាញទំនាក់ទំនង ។
- ធ្វើឲ្យប្រាកដឡើងនូវទស្សនៈវិស័យ នៃការផ្តល់នូវសេវាកម្មអប់រំ ប្រកបដោយគុណភាពខ្ពស់បំផុត។ កំណត់នូវភាពលេចធ្លោ សម្រាប់ស្ថាប័នរបស់ខ្លួននៅក្នុងទីផ្សារថា ជាគ្រឹះស្ថានអប់រំ ប្រកបដោយ វិន័យ និងសីលធម៌ខ្ពស់ ដែលផ្តល់តម្លៃដ៏វិសេសវិសាលដល់បទដ្ឋានសិក្សាធិការ និងវិជ្ជាជីវៈ ។

តាងនាមឱ្យក្រុមប្រឹក្សាភិបាល នៃ វិទ្យាស្ថាន ពាណិជ្ជសាស្ត្រ អេស៊ីលីដា ខ្ញុំសូមសម្តែងនូវគារវកិច្ច និងអំណរគុណយ៉ាងជ្រាលជ្រៅ ចំពោះធនាគារ អេស៊ីលីដា ភីអិលស៊ី ដែលជាក្រុមហ៊ុនមេ អតិថិជន សិស្ស-និស្សិត អាណាព្យាបាល និងសាធារណជន ព្រមទាំងដៃគូជាតិ អន្តរជាតិ ជាពិសេសរាជរដ្ឋាភិបាលកម្ពុជាដែលបានផ្តល់ការជឿទុកចិត្ត និងគាំទ្រដល់ វិទ្យាស្ថាន ពាណិជ្ជសាស្ត្រ អេស៊ីលីដា ក្នុងបេសកកម្មអប់រំ-បណ្តុះបណ្តាលធនធានមនុស្សកន្លងមក ។ម្យ៉ាងវិញទៀត ខ្ញុំក៏សូមសម្តែងនូវអំណរគុណ និងកោតសរសើរ ចំពោះសមាជិក-សមាជិកា ក្រុមប្រឹក្សាភិបាល ក៏ដូចជាថ្នាក់ដឹកនាំ និងកម្មករនិយោជិតគ្រប់ជាន់ថ្នាក់ នៃវិទ្យាស្ថាន ពាណិជ្ជសាស្ត្រ អេស៊ីលីដា ដែលមានការប្តេជ្ញាចិត្តខ្ពស់ និងទទួលជោគជ័យ ក្នុងការបំពេញកិច្ចការងារមួយឆ្នាំកន្លងមកនេះ ។

ទីបញ្ចប់ ខ្ញុំសូមបួងសួងសូមឱ្យលោកអ្នក ព្រមទាំងក្រុមគ្រួសារទាំងអស់ ទទួលបាននូវសុខភាពល្អ សិរីសួស្តី ជោគជ័យមង្គល និងវិបុលសុខជានិច្ចនិរន្តរ៍តរៀងទៅ ។

អេស៊ីលីដា
ACLEDA

បណ្ឌិត សូ ផនណារី
*ប្រធានក្រុមប្រឹក្សាភិបាល*

ថ្ងៃទី០៩ ខែមីនា ឆ្នាំ២០១៨

# វេទិកាលើកទី៨ៃចអ្នកដឹកនាំ



## លោក ឆន ពន្លឺ

នាយកវិទ្យាស្ថាន

ស្ថិតនៅលើវិថីនៃការផ្ដល់សេវាអប់រំ ឧត្តមសិក្សា នាដំណាក់កាលដំបូងៗរបស់ខ្លួន ថ្នាក់ដឹកនាំ និងកម្មករនិយោជិតគ្រប់លំដាប់ថ្នាក់នៃវិទ្យាស្ថាន ពាណិជ្ជសាស្ត្រ អេស៊ីលីដា បានប្រឹងប្រែងរៀនសូត្រពីការងារថ្មីៗ និងព្យាយាមជម្នះរាល់ឧបសគ្គ ដោយឆន្ទៈមនសិការការងារ និងការទទួលខុសត្រូវខ្ពស់ ជាមួយនឹងការប្ដេជ្ញាចិត្តក្នុងការរក្សាឲ្យបាននូវទំនុកចិត្តលើគុណភាពសេវាកម្មរបស់ខ្លួន ពីសំណាក់សិស្ស-និស្សិត ព្រមទាំងអាណាព្យាបាល និងជាពិសេស ក្រសួងអប់រំ យុវជន និងកីឡា ឲ្យស្របជាមួយនឹងគតិពេចន៍ "ថ្នាលអប់រំដែលលោកអ្នកជឿទុកចិត្ត!" ។

ដើម្បីធ្វើឲ្យនិស្សិតដែលបញ្ចប់ការសិក្សា មានសក្ដានុពល ការងារខ្ពស់ និងទទួលបាននូវភាពជោគជ័យ ក្នុងអាជីពការងាររបស់ខ្លួន វិទ្យាស្ថានជានិច្ចកាល ប្ដេជ្ញាចិត្ត ក្នុងការបង្កើតបរិយាកាសសិក្សារៀនសូត្រល្អ បំពាក់សិក្ខូបករណ៍ទំនើបទាន់សម័យ ប្រើប្រាស់កម្មវិធីសិក្សាស្តង់ដារអន្តរជាតិ និងសាស្ត្រាចារ្យដែលមានគុណវុឌ្ឍិគ្រប់គ្រាន់ ព្រមទាំងការផ្ដល់សេវាកម្មនិស្សិត ប្រកបដោយគុណភាពខ្ពស់ ដើម្បីអភិវឌ្ឍចំណេះដឹង ជំនាញវិជ្ជាជីវៈ បទពិសោធន៍ អភិសមាចារ និងបណ្ដាញទំនាក់ទំនង ដល់និស្សិតរបស់ខ្លួន ។

## សមិទ្ធផលសម្រេចបានក្នុងឆ្នាំ២០១៧

### ការគ្រប់គ្រងកិច្ចការបណ្ដុះបណ្ដាល

- បានចាត់ចែងអភិវឌ្ឍន៍ និងធ្វើបច្ចុប្បន្នកម្មលើគោលការណ៍ នីតិវិធី និងកម្មវិធីសិក្សា នៃវគ្គហ្វឹកហ្វឺនកម្មករនិយោជិតថ្មី និងវគ្គបណ្ដុះបណ្ដាលកម្មករនិយោជិតដែលកំពុងបម្រើការងារ ដោយសហការជាមួយនាយកដ្ឋានការិយាល័យដែលពាក់ព័ន្ធ ដើម្បីធានាបាននូវភាពទាន់សម័យ ស្របទៅតាមតម្រូវការរបស់សិក្ខាកាម និងវិវឌ្ឍនាការរបស់ ធនាគារ អេស៊ីលីដា ភីអិលស៊ី ។
- បានបណ្ដុះបណ្ដាលគ្រូហ្វឹកហ្វឺនថ្មីបន្ថែមទៀត ចំនួន ១៤៧នាក់ (គ្រូហ្វឹក-ហ្វឺននៅការិយាល័យកណ្ដាល ចំនួន ៦៣នាក់ នៅសាខា ចំនួន៧៥នាក់ និងនៅ វិទ្យាស្ថាន ពាណិជ្ជសាស្ត្រ អេស៊ីលីដា ចំនួន ០៩នាក់) ដើម្បីលើកស្ទួយគុណភាព និងប្រសិទ្ធភាពនៃការបណ្ដុះបណ្ដាល ឆ្លើយតបទៅនឹងតម្រូវការ និងការវិវឌ្ឍថ្មីៗ របស់អតិថិជនខាងក្នុង និងខាងក្រៅ ។
- បានចាត់ចែងការបណ្ដុះបណ្ដាល ដល់កម្មករនិយោជិត ធនាគារ អេស៊ីលីដា ភីអិលស៊ី និងក្រុមហ៊ុនបុត្រសម្ព័ន្ធក្រៅប្រទេស ចំនួន ៦.១៧៥វគ្គ ដោយមានសិក្ខាកាមចូលរួមសរុប ចំនួន ៦៥.៤៥៩នាក់ ។ ជាមធ្យមនៅក្នុងឆ្នាំ ២០១៧ បុគ្គលិកធនាគារ អេស៊ីលីដា ភីអិលស៊ី ម្នាក់ៗ ទទួលបានការបណ្ដុះបណ្ដាល ចំនួន ៥ដង ។
- បានបន្តសុពលភាព និងបានចុះអនុស្សារណៈយោគយល់គ្នាថ្មីៗ បន្ថែមជាមួយគ្រឹះស្ថានធនាគារ មីក្រូហិរញ្ញវត្ថុ អង្គការ ប្រតិបត្តិការឥណទាន គ្រឹះស្ថានសិក្សា និងក្រុមហ៊ុនឯកជនផ្សេងៗទៀត សរុបចំនួន ៦៨ (គិតត្រឹមខែធ្នូឆ្នាំ២០១៧) ដើម្បីផ្ដល់ឱកាសការងារដល់និស្សិតដែលបានបញ្ចប់ដោយជោគជ័យ ក្នុងវគ្គសិក្សាអភិវឌ្ឍន៍ជំនាញខ្លីៗ របស់វិទ្យាស្ថាន ពាណិជ្ជសាស្ត្រ អេស៊ីលីដា ។
- បានបន្តផ្ដល់ការហ្វឹកហ្វឺន ចែករំលែកបទពិសោធន៍ ដ៏ជោគជ័យរបស់ធនាគារ អេស៊ីលីដា ភីអិលស៊ី ជូនដល់សិក្ខាកាមជានិស្សិត និងសិក្ខាកាមមកពីបណ្ដាក្រុមហ៊ុន អង្គការ ស្ថាប័នធនាគារ ហិរញ្ញវត្ថុជាតិ និងអន្តជាតិ សរុបចំនួន ៤០ វគ្គ ដោយមានសិក្ខាកាមចូលរួមសរុបចំនួន ៨១៥ នាក់ ។

## កិច្ចការអប់រំសិក្សា

- វិទ្យាស្ថាន បានរៀបចំវគ្គសិក្ខាសាលាជាបន្តបន្ទាប់ ស្តីពី Professional Development Program ដល់ក្រុមគ្រូបង្រៀនអេស៊ីលីដា សរុបចំនួន ៤២នាក់ ដើម្បីបង្កើនចំណេះដឹង ជំនាញក្នុងការបង្រៀន និងដើម្បីធានាដល់គុណភាពនៃការផ្តល់នូវសេវាកម្មអប់រំ ប្រកបដោយជំនាញវិជ្ជាជីវៈ និងគរុកោសល្យ ។
- បានចាត់បញ្ជូនថ្នាក់គ្រប់គ្រង និងមន្ត្រីជំនាញពាក់ព័ន្ធរបស់វិទ្យាស្ថាន សរុបចំនួន ១០នាក់ ឲ្យចូលរួមវគ្គបណ្តុះបណ្តាល និងវគ្គសិក្ខាសាលា ចំនួន ៥វគ្គ ដែលរៀបចំឡើងដោយ ក្រសួងអប់រំ យុវជន និងកីឡា សមាគមគ្រឹះស្ថានឧត្តមសិក្សា និងស្ថាប័នជំនាញផ្សេងៗទៀត ដើម្បីធានាបាននូវអនុលោមភាព និងភាពទាន់សម័យ នៃប្រតិបត្តិការសេវាកម្មអប់រំ ។
- បានចាត់បញ្ជូនប្រតិភូជាថ្នាក់គ្រប់គ្រង ចំនួន ៤នាក់ ឲ្យចូលរួមវគ្គទស្សនកិច្ចសិក្សាដោយផ្ទាល់នៅ Ross School of Business (RSB) នៃ University of Michigan ដើម្បីបង្កើតទស្សនវិស័យស្តីពី របៀបដែលសាលាធុរកិច្ចលំដាប់ថ្នាក់ពិភពលោក កំពុងធ្វើប្រតិបត្តិការ ពិនិត្យសង្កេតលើយុទ្ធសាស្ត្រ ជាមូលដ្ឋាន និងការអនុវត្តយុទ្ធសាស្ត្ររបស់ RSB ព្រមទាំងដកស្រង់បទពិសោធន៍ល្អៗ ដែលមានគុណប្រយោជន៍សម្រាប់យកមកអភិវឌ្ឍ វិទ្យាស្ថាន ពាណិជ្ជសាស្ត្រ អេស៊ីលីដា ។
- តាមរយៈការចុះកិច្ចព្រមព្រៀងកម្ចីឥណទានពី សាជីវកម្មហិរញ្ញវត្ថុអន្តរជាតិ (International Financial Corporation: IFC) ចំនួន១៣លាន ដុល្លារអាមេរិក រហូតមកដល់ថ្ងៃទី ៣១ ខែធ្នូ ឆ្នាំ២០១៧ នេះវិទ្យាស្ថានបានប្រើប្រាស់ ប្រាក់កម្ចី ពី IFC ចំនួន៥លាន ដុល្លារអាមេរិក ដើម្បីគាំទ្រដល់ដំណើរការសាងសង់អគារវិទ្យាស្ថានកម្រិតស្តង់ដារអន្តរជាតិ ។
- រហូតមកដល់ដំណាច់ឆ្នាំ២០១៧ នេះ ក្រុមហ៊ុន អ៊ី & អេ ខនសាល់ធេន (E & A Consultant) បានបញ្ចប់ការសិក្សា និងវាយតម្លៃ លើហេតុប៉ះពាល់បរិស្ថាន និងសង្គមពេញលេញរួចហើយ ។ ក្រុមហ៊ុនបានបញ្ជូនរបាយការណ៍ និងពាក្យស្នើសុំការអនុញ្ញាតជាគោលការណ៍ ដាក់ជូនឯកឧត្តមរដ្ឋមន្ត្រីក្រសួងបរិស្ថាន ដើម្បីពិនិត្យនិងសម្រេច ។ ជាសរុប កិច្ចការនេះសម្រេចបាន ៩០ ភាគរយហើយ ។
- មកដល់ថ្ងៃទី ៣១ ខែធ្នូ ឆ្នាំ២០១៧ នេះ កិច្ចការសាងសង់អគារវិទ្យាស្ថាន ពាណិជ្ជសាស្ត្រ អេស៊ីលីដា ដោយក្រុមហ៊ុនសាជីវកម្មពិស្ណុការអន្តរជាតិ (PISNOKA International Corporation) គឺសម្រេចបាន ៣៩.២០% នៃការងារសរុបហើយ ក្នុងនោះរួមមាន៖ អគាររដ្ឋបាល សម្រេចបាន ៣៦%, អគារសិក្សាទី១ សម្រេចបាន៤៣%, អគារសិក្សាទី២ សម្រេចបាន៣៩%, អគារបណ្ណាល័យ សម្រេចបាន៤៣%, អគារអន្តេវាសិកដ្ឋាន សម្រេចបាន ៤២% ។ ចំពោះតម្លៃសាងសង់បានកើនឡើងពី ១៨,២៦០,០០០ ដុល្លារអាមេរិក ទៅ ១៨,៣០១,៥៥៨.៣៩ ដុល្លារអាមេរិក ដោយសារមានការកែសម្រួលគ្រឹះអគាររដ្ឋបាល និងអគារសិក្សាទី២ ចំនួន ៤១,៥៥៨.៣៩ ដុល្លារអាមេរិក រួមទាំងពន្ធអាករ (VAT) ១០% ។
- ដើម្បីចូលរួមក្នុងការលើកកម្ពស់វិស័យអប់រំ សម្រាប់ប្រយោជន៍ជាតិ វិទ្យាស្ថាន ពាណិជ្ជសាស្ត្រ អេស៊ីលីដា បានបន្តសហការជាមួយ ធនាគារ អេស៊ីលីដា ភីអិលស៊ី ក្នុងការផ្តល់ឥណទាននិស្សិតដែលមានរយៈពេលវែងរហូតដល់៨ឆ្នាំ ជាមួយនឹងអត្រាការប្រាក់កាន់តែទាបជាងមុន និងរបៀបសងត្រឡប់ដែលមានភាពលក្ខណៈអនុគ្រោះខ្ពស់ ដើម្បីបើកឱកាសឱ្យនិស្សិតទាំងអស់ ទាំងនិស្សិតដែលមានលទ្ធភាព និងមិនមានលទ្ធភាពបង់ថ្លៃសិក្សា សុទ្ធតែមានឱកាសសិក្សានៅ វិទ្យាស្ថាន ពាណិជ្ជសាស្ត្រ អេស៊ីលីដា ដូចៗគ្នាផងដែរ ។
- បានកែសម្រួលអនុស្សារណៈនៃការយោគយល់គ្នា ជាមួយធនាគារ អេស៊ីលីដា ភីអិលស៊ី ដើម្បីផ្តល់ឱកាសដល់និស្សិតរបស់ វិទ្យាស្ថាន ពាណិជ្ជសាស្ត្រ អេស៊ីលីដា អាចធ្វើទស្សនកិច្ចសិក្សា ចុះហាត់ការដោយផ្ទាល់នៅតាមបណ្តាសាខា និងការិយាល័យកណ្តាល នៃធនាគារ អេស៊ីលីដា ភីអិលស៊ី និងការសិក្សាជាមួយសាស្ត្រាចារ្យដែលកំពុងបម្រើការងារដោយជោគជ័យ នៅក្នុងធនាគារ អេស៊ីលីដា ភីអិលស៊ី ។
- បានទទួលនូវការអនុញ្ញាតជាផ្លូវការលើការផ្សព្វផ្សាយពាណិជ្ជកម្មសេវាអប់រំកម្រិតឧត្តមសិក្សា ស្របតាមបញ្ញត្តិរបស់ក្រសួងអប់រំ យុវជន និងកីឡា តាមរយៈទិដ្ឋាការអនុញ្ញាតលេខ០២/២០១៧គ.ព.ខ.រ.ផ ។
- បានទទួលនិស្សិតចុះឈ្មោះបន្ថែមចំនួន២១៧នាក់ (ថ្នាក់បរិញ្ញាបត្ររង ចំនួន ៥៤នាក់ និងថ្នាក់បរិញ្ញាបត្រ ចំនួន ១៦៣នាក់) ឲ្យចូលសិក្សាសម្រាប់ឆ្នាំសិក្សា ២០១៧-២០១៨ ក្នុងនោះវិទ្យាស្ថានបានផ្តល់អាហាររូបករណ៍ប្រភេទ"ក" (១០០% បូកប្រាក់ឧបត្ថម្ភ៤,៨០០ដុល្លារ), ប្រភេទ"ខ" (១០០%), ប្រភេទ"គ" (៥០%) និងប្រភេទ"ឃ" (២៥%) ដល់និស្សិតសរុប ចំនួន២៣នាក់ ។
- បានទទួលការអនុម័តជាគោលការណ៍ ពីក្រុមប្រឹក្សាភិបាល ដើម្បីលើកសំណើបន្តទៅភាគទុនិក លើសំណើសុំបង្កើនដើមទុនបន្ថែមចំនួន ២លានដុល្លារអាមេរិក និងកម្ចីរយៈពេលវែង ចំនួន ៥លានដុល្លារអាមេរិក សម្រាប់គាំទ្រដល់ដំណើរការសាងសង់អគារវិទ្យាស្ថាន ពាណិជ្ជសាស្ត្រ អេស៊ីលីដា ។

## លទ្ធផលប្រតិបត្តិការក្នុងឆ្នាំ២០១៧

- ទ្រព្យសកម្មសរុបកើនឡើងពី ២៦.៦០៥.៩៤៩ ដុល្លារអាមេរិក រហូតដល់ ២៧.៦៤៩.១៣១ ដុល្លារអាមេរិក ។
- មូលនិធិម្ចាស់ហ៊ុនកើនឡើងពី ២០.៨៦២.៩៩២ ដុល្លារអាមេរិក រហូតដល់ ២១.០២៤.៦២៤ ដុល្លារអាមេរិក ។
- អនុបាតប្រសិទ្ធភាពប្រតិបត្តិការបានថយចុះពី ៧២,៣៣%មកនៅត្រឹម៦០,៣៥%។
- អត្រាប្រាក់ចំណូលដែលបានមកពីការហ្វឹកហ្វឺន និងបណ្តុះបណ្តាល សិក្ខាកាមមកពីខាងក្រៅ រួមនឹងចំណូលផ្សេងៗ ធៀបនឹងចំណូលដុល បានកើនឡើងពី ១៧,៣៦% រហូតដល់ ២២,៤៧%។

- ប្រាក់ចំណេញក្នុងឆ្នាំប្រតិបត្តិការចំនួន ១៦១.៦៣២ ដុល្លារអាមេរិក
- ការបណ្តុះបណ្តាលកម្មករនិយោជិតធនាគារ អេស៊ីលីដា ភីអិលស៊ី សម្រាប់ឆ្នាំ ២០១៧ ៖
  - វគ្គហ្វឹកហ្វឺនកម្មករនិយោជិតថ្មី ចំនួន ៣១ វគ្គ សរុបសិក្ខាកាម ចំនួន ១.១៧៩ នាក់
  - វគ្គហ្វឹកហ្វឺនការងារដំបូង ចំនួន ១.០៥៩ វគ្គ សរុបសិក្ខាកាម ចំនួន ១.២៤២ នាក់
  - វគ្គបណ្តុះបណ្តាលកម្មករនិយោជិតដែលកំពុងបម្រើការងារ ចំនួន ៥.០៨៣ វគ្គ សរុបសិក្ខាកាម ចំនួន ៦៣.០២៩ នាក់
  - វគ្គបណ្តុះបណ្តាលជំនាញគ្រូហ្វឹកហ្វឺនថ្មី ចំនួន ០៣ វគ្គ សរុបសិក្ខាកាម ចំនួន ១៤៧ នាក់
- ការបណ្តុះបណ្តាលកម្មករនិយោជិតក្រុមហ៊ុនបុត្រសម្ព័ន្ធក្រៅប្រទេស ធនាគារ អេស៊ីលីដា ភីអិលស៊ី ៖
  - វគ្គហ្វឹកហ្វឺននៅនឹងកន្លែងការងារ ចំនួន ០១ វគ្គ សរុបសិក្ខាកាម ចំនួន ០១ នាក់
  - វគ្គហ្វឹកហ្វឺននៅក្នុងថ្នាក់ ចំនួន ០១ វគ្គ សរុបសិក្ខាកាម ចំនួន ០៨ នាក់
- ការបណ្តុះបណ្តាល និងចែករំលែកបទពិសោធន៍ សម្រាប់ស្ថាប័នខាងក្រៅ ៖
  - វគ្គសិក្ខាសាលាសម្រាប់ស្ថាប័នក្នុងស្រុក ចំនួន ២៩ វគ្គ សរុបសិក្ខាកាម ចំនួន ៦៧៥ នាក់
  - វគ្គទស្សនកិច្ចសិក្សាសម្រាប់ស្ថាប័នពីក្រៅប្រទេស ចំនួន ០៤ វគ្គ សរុបអ្នកចូលរួម ចំនួន ៥៧ នាក់
- វគ្គបណ្តុះបណ្តាលជំនាញសម្រាប់និស្សិត ចំនួន ០៧ វគ្គ សរុបសិក្ខាកាម ចំនួន ៨៣ នាក់ ។
- កម្មវិធីថ្នាក់ឧត្តមសិក្សា
  - ថ្នាក់បំប៉ន ចំនួន ៣៨ ថ្នាក់ សរុបនិស្សិតចំនួន ៧៦៤ នាក់ ។
  - ថ្នាក់បរិញ្ញាបត្ររង ចំនួន ០៧ ថ្នាក់ សរុបនិស្សិតចំនួន ១៤២ នាក់ ។
  - ថ្នាក់បរិញ្ញាបត្រ ចំនួន ២១ ថ្នាក់ សរុបនិស្សិតចំនួន ៤៨៨ នាក់ ។
- វគ្គសិក្សាភាសាអង់គ្លេសទូទៅ ចំនួន ៤០ ថ្នាក់ សរុបសិក្ខាកាម ចំនួន ៤២៨ នាក់ ។

## យុទ្ធសាស្ត្រអាទិភាពសម្រាប់ឆ្នាំ២០១៨ និងឆ្នាំបន្តបន្ទាប់

- បន្តផ្តោតទៅលើការវិនិយោគលើធនធានមនុស្ស តាមរយៈការកសាងសមត្ថភាពបន្ថែម ដល់ថ្នាក់គ្រប់គ្រង សាស្ត្រាចារ្យ និងបុគ្គលិកជំនាញ ដែលពាក់ព័ន្ធទាំងចំណេះដឹងជំនាញ និងចំណេះដឹងភាសាយាន ដើម្បីឲ្យធនធានមនុស្សរបស់ វិទ្យាស្ថាន ពាណិជ្ជសាស្ត្រ អេស៊ីលីដា បំពេញការងារប្រកបដោយភាពជំនាញវិជ្ជាជីវៈ គុណភាព ប្រសិទ្ធភាព និងផលិតភាពការងារខ្ពស់ ធានាបាននូវបណ្តុះសេវាកម្មអប់រំ បណ្តុះ-បណ្តាល ប្រកបដោយគុណភាពខ្ពស់បំផុត ។
- បង្កើនចំនួននិស្សិតចុះឈ្មោះ ដោយការបន្ថែមនូវជំនាញដទៃក្រៅពីជំនាញហិរញ្ញវត្ថុ និងធនាគារ ព្រមទាំងអភិវឌ្ឍកម្មវិធីសិក្សានីមួយៗឲ្យបានល្អបំផុត និងបំពេញតាមស្តង់ដារ ដែលមានគុណភាពអន្តរជាតិ ។
- ជ្រើសរើសគ្រូបង្រៀន ដែលមានបទពិសោធន៍ជោគជ័យជាមួយធនាគារ អេស៊ីលីដា បន្ថែមព្រមទាំងកសាងសមត្ថភាពរបស់ពួកគាត់ជាមួយនឹងគរុកោសល្យក្នុងការបង្រៀនទាន់សម័យ ដើម្បីប្រែក្លាយពួកគាត់ ជាគ្រូបង្រៀនកម្មវិធី Academic ឲ្យបានឆាប់ៗតាមដែលអាចធ្វើបាន ។
- សិក្សាលើតម្រូវការ និងលក្ខណៈវិនិច្ឆ័យនៃស្ថាប័នទទួលស្គាល់គុណភាពអប់រំ ដោយចាប់ផ្តើមពី កម្រិតថ្នាក់ជាតិ ដល់ថ្នាក់តំបន់ ដើម្បីបង្កើតសកម្មភាពការងារ និងបង្កើនកិច្ចខិតខំប្រឹងប្រែងរបស់ វិទ្យាស្ថាន ពាណិជ្ជសាស្ត្រ អេស៊ីលីដា រៀបចំខ្លួនឲ្យមានលក្ខណៈសម្បត្តិគ្រប់គ្រាន់ សម្រាប់ការដាក់ពាក្យស្នើសុំទទួលស្គាល់គុណភាពពីស្ថាប័នទាំងនោះ ។
- ធ្វើឲ្យប្រាកដឡើងនូវទស្សនវិស័យ នៃការផ្តល់នូវសេវាកម្មអប់រំប្រកបដោយគុណភាពខ្ពស់បំផុត ។ កំណត់នូវភាពលេចធ្លោសម្រាប់ស្ថាប័នរបស់ខ្លួននៅក្នុងទីផ្សារ ថាជាគ្រឹះស្ថានអប់រំប្រកបដោយ វិន័យ និងសីលធម៌ខ្ពស់ ដែលផ្តល់តម្លៃដ៏វិសេសវិសាល ដល់បទដ្ឋានសិក្សាធិការ និងវិជ្ជាជីវៈ ។
- អភិវឌ្ឍន៍សេវាកម្មហ្វឹកហ្វឺនថ្មីៗបន្ថែម និងបង្កើនការលក់សេវាអប់រំបណ្តុះបណ្តាលដល់អតិថិជនខាងក្រៅនិងនិស្សិត ដើម្បីទទួលបាននូវអត្រាប្រាក់ចំណូលដែលមានប្រភពមកពីខាងក្រៅ រួមនឹងចំណូលផ្សេងៗធៀបនឹងចំណូលដុល ធំជាង ៤៥% ។
- បង្កើនប្រសិទ្ធភាពនៃការគ្រប់គ្រងចំណាយ កាត់បន្ថយនូវចំណាយមិនចាំបាច់តាមរយៈការសន្សំសំចៃការប្រើប្រាស់ឧបករណ៍ និងសម្ភារទូទៅ ដើម្បីរក្សាបាននូវអនុបាតប្រសិទ្ធភាពប្រតិបត្តិការឲ្យនៅទាបជាង ៤៥% ។

ជាចុងបញ្ចប់ ខ្ញុំសូមសម្តែងនូវគារវកិច្ច និងកតញ្ញូយ៉ាងជ្រាលជ្រៅ ចំពោះសិស្ស-និស្សិត អាណាព្យាបាល អតិថិជនដ៏ឆ្លាតវៃ ក្រុមហ៊ុនមេ ក្រុមប្រឹក្សាភិបាល ក្រុមប្រឹក្សាយោបល់ ថ្នាក់គ្រប់គ្រង សាស្ត្រាចារ្យ និងបុគ្គលិកគ្រប់ជាន់ថ្នាក់ ព្រមទាំងដៃគូជាតិ និងអន្តរជាតិ និងជាពិសេសរាជរដ្ឋាភិបាលកម្ពុជា ដែលបានផ្តល់ទំនុកចិត្ត និងផ្តល់ការគាំទ្រយ៉ាងកក់ក្តៅដល់ វិទ្យាស្ថាន ពាណិជ្ជសាស្ត្រ អេស៊ីលីដា ក្នុងបេសកកម្មអប់រំបណ្តុះបណ្តាលធនធានមនុស្សកន្លងមក ។

ខ្ញុំសូមបួងសួងឲ្យលោកអ្នក និងក្រុមគ្រួសារទទួលបាននូវសេចក្តីសុខកាយ សប្បាយចិត្ត ចម្រើនដោយប្រយោជន៍ ជោគជ័យក្នុងនាទីការងារ និងមុខជំនួញប្រកបដោយគុណភាព និងប្រសិទ្ធភាពដ៏ឧត្តុង្គឧត្តម កុំបីឃ្លៀងឃ្លាត ។

ACLEDA

លោក ឆន ពន្លឺ
នាយកវិទ្យាស្ថាន
ថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០១៧

# អង្គការលេខ


ក្រុមប្រឹក្សាភិបាល
គណៈកម្មាធិការសិក្សាធិការ នៃក្រុមប្រឹក្សាភិបាល
គណៈកម្មាធិការសវនកម្ម សីលធម៌ និង សម្រប សម្រួលកិច្ចការច្បាប់ នៃក្រុមប្រឹក្សាភិបាល
ក្រុមប្រឹក្សាវិន័យ
នាយក-នាយិកា
គណៈកម្មាធិការប្រតិបត្តិ
ទីប្រឹក្សា
គណៈកម្មាធិការ សិក្សាធិការ
គណៈកម្មាធិការ កំណត់ថ្លៃ
ផ្នែក សវនកម្មផ្ទៃក្នុង
នាយក-នាយិការង
ផ្នែកធានា គុណភាពផ្ទៃក្នុង
ផ្នែក គ្រប់គ្រងបណ្ណាល័យ
ការិយាល័យ ទំនាក់ទំនងសាធារណៈ
ផ្នែកទំនាក់ទំនង និង សហប្រតិបត្តិការ
ផ្នែកទីផ្សារ
ភ្នាក់ងារ គ្រប់គ្រងហានិភ័យ
ការិយាល័យ ផែនការ និង ហិរញ្ញវត្ថុ
ផ្នែកគណនេយ្យ
ផ្នែកផែនការថវិកា
ផ្នែកលេខាធិការ
ការិយាល័យ បុគ្គលិក និង រដ្ឋបាល
ផ្នែកបុគ្គលិក និង រដ្ឋបាល
ភ្នាក់ងារបច្ចេកវិទ្យាព័ត៌មាន
មជ្ឈមណ្ឌល ហ្វឹកហ្វឺន
ផ្នែកហ្វឹកហ្វឺន
ផ្នែកអភិវឌ្ឍន៍ការហ្វឹកហ្វឺន
ការិយាល័យសិក្សា និង កិច្ចការនិស្សិត
ផ្នែកចុះឈ្មោះ និង បញ្ជិកា
ផ្នែកគាំទ្រការសិក្សា និង កិច្ចការនិស្សិត
ផ្នែកស្រាវជ្រាវ
ដេប៉ាតឺម៉ង់ គ្រប់គ្រងពាណិជ្ជកម្ម
ផ្នែកទំនាក់ទំនង និង រៀបចំគ្រូបង្រៀន
ផ្នែកគ្រប់គ្រងកម្មវិធី ថ្នាក់ឧត្តមសិក្សា
គ្រូបង្រៀន
ដេប៉ាតឺម៉ង់ ថ្នាក់ឆ្នាំសិក្សាមូលដ្ឋាន
ផ្នែកគ្រប់គ្រងកម្មវិធី ថ្នាក់ឆ្នាំសិក្សាមូលដ្ឋាន
គ្រូបង្រៀន
មជ្ឈមណ្ឌលសម្រាប់ កែលម្អគុណភាពជំនាញ

# ភាគទុនិក



## បណ្ឌិត អ៊ិន ចាន់នី

តំណាងភាគទុនិក

វិទ្យាស្ថាន ពាណិជ្ជសាស្ត្រ អេស៊ីលីដា ជាសហគ្រាសឯកបុគ្គលទទួលខុសត្រូវមានកម្រិត ដែលបានចុះបញ្ជីពាណិជ្ជកម្ម ដោយគោរពទៅតាមច្បាប់នៃ ព្រះរាជាណាចក្រកម្ពុជា ។ វិទ្យាស្ថាន ពាណិជ្ជសាស្ត្រ អេស៊ីលីដា មានការិយាល័យ ស្ថិតនៅអគារលេខ៥០ ផ្លូវលេខ៥១៦ កែង៣៣៥ ភូមិ៦ សង្កាត់បឹងកក់១ ខណ្ឌទួលគោក រាជធានីភ្នំពេញ និងមានភាគទុនិកកាន់កាប់ភាគហ៊ុន ១០០ ភាគរយ ដោយធនាគារ អេស៊ីលីដា ភីអិលស៊ី ជាក្រុមហ៊ុនមេ តំណាងដោយ លោកបណ្ឌិត អ៊ិន ចាន់នី ។

ភាគទុនិក គឺជាម្ចាស់របស់ វិទ្យាស្ថាន ពាណិជ្ជសាស្ត្រ អេស៊ីលីដា ។ ភាគទុនិកមានសិទ្ធិអនុម័តលើយុទ្ធសាស្ត្រនានា ប៉ុន្តែភាគទុនិក ពុំមានសិទ្ធិអំណាចគ្រប់គ្រងផ្ទាល់លើការងារទាំងអស់នេះទេ ទោះបីជាយ៉ាងណាក៏ដោយ ភាគទុនិកអាចផ្ទេរការទទួលបន្ទុកទាំងនេះ ទៅឱ្យ ក្រុមប្រឹក្សាភិបាល តាមរយៈអនុស្សរណៈ និងលក្ខន្តិកៈ របស់ វិទ្យាស្ថាន ពាណិជ្ជសាស្ត្រ អេស៊ីលីដា ។

## ធនាគារ អេស៊ីលីដា ភីអិលស៊ី

ធនាគារ អេស៊ីលីដា ភីអិលស៊ី ជាក្រុមហ៊ុនមហាជនទទួលខុសត្រូវមានកម្រិត ដែលបានបង្កើតឡើង តាមប្រព័ន្ធច្បាប់គ្រឹះស្ថានធនាគារ និងហិរញ្ញវត្ថុនៃព្រះរាជាណាចក្រកម្ពុជា ។ ធនាគារ អេស៊ីលីដា បានចាប់បដិសន្ធិឡើងនៅក្នុងខែមករា ឆ្នាំ១៩៩៣ ក្នុងនាមជាអង្គការក្រៅរដ្ឋាភិបាលមួយ ដែលមានទិសដៅអភិវឌ្ឍន៍មុខរបរខ្នាតតូចបំផុត និងខ្នាតតូច តាមរយៈការផ្តល់ឥណទាន ។

នៅថ្ងៃទី០៧ ខែតុលា ឆ្នាំ២០០០ ធនាគារ អេស៊ីលីដា បានទទួលអាជ្ញាប័ណ្ណជាធនាគារឯកទេសពីធនាគារជាតិនៃកម្ពុជា ។ នៅថ្ងៃទី០១ ខែធ្នូ ឆ្នាំ២០០៣ ធនាគារ អេស៊ីលីដា បានទទួលអាជ្ញាប័ណ្ណជាធនាគារពាណិជ្ជ ពី ធនាគារជាតិនៃកម្ពុជា ដែលធ្វើឱ្យធនាគារ អេស៊ីលីដា មានលទ្ធភាពបំពេញទៅតាមតម្រូវការរបស់អតិថិជននូវសេវាធនាគារបានទូទៅ និងទូលំទូលាយថែមទៀត ហើយក៏បានប្តូរឈ្មោះជាផ្លូវការមកជា "ធនាគារ អេស៊ីលីដា ភីអិលស៊ី" ។

នៅចុងខែធ្នូ ឆ្នាំ២០១៧ ធនាគារ អេស៊ីលីដា ភីអិលស៊ី មានបណ្តាញប្រតិបត្តិការ ចំនួន ២៦១ សាខា កម្មករនិយោជិត ចំនួន ១២.៤៥៦ នាក់ និងមានទ្រព្យសកម្មសរុប ចំនួន ៥.២៤៤,៣៧ លានដុល្លារអាមេរិក ។

ព័ត៌មានបន្ថែមសូមចូលទស្សនាគេហទំព័រៈ www.acledabank.com.kh

ជនជាតិខ្មែរ កើតក្នុងខែមិថុនា ឆ្នាំ១៩៦០ ។ បណ្ឌិត អ៊ិន ចាន់នី ជាប្រធាននាយកប្រតិបត្តិ របស់ធនាគារ អេស៊ីលីដា ភីអិលស៊ី ចាប់តាំងពីធនាគារបានបង្កើតឡើងនៅក្នុងឆ្នាំ២០០០ ។ លោកបណ្ឌិតបានក្លាយជាសមាជិកក្រុមប្រឹក្សាភិបាលរបស់ ធនាគារ អេស៊ីលីដា ភីអិលស៊ី នៅខែកញ្ញា ឆ្នាំ២០១៤ ។ បណ្ឌិត អ៊ិន ចាន់នី ជាសហស្ថាបនិករបស់ សមាគមទីភ្នាក់ងារអភិវឌ្ឍន៍សេដ្ឋកិច្ចកម្ពុជា (អេស៊ីលីដា) តាំងពីខែមករា ឆ្នាំ១៩៩៣ ។ ក្នុងតួនាទីជាប្រធាននាយកប្រតិបត្តិ លោកបណ្ឌិត ជាអ្នកដឹកនាំគណៈកម្មាធិការប្រតិបត្តិ ទទួលខុសត្រូវរៀបចំផែនការយុទ្ធសាស្ត្ររួម និងដំណើរការងារអាជីវកម្មប្រចាំថ្ងៃរបស់ធនាគារ អេស៊ីលីដា ភីអិលស៊ី និងបុគ្រសម្ព័ន្ធព្រមទាំងប្រតិបត្តិផែនការអាជីវកម្ម ។ លោកបណ្ឌិតទទួលខុសត្រូវផ្ទាល់ចំពោះក្រុមប្រឹក្សាភិបាល ។

ទំនួលខុសត្រូវផ្សេងទៀតរបស់លោកបណ្ឌិត រួមមាន ជាប្រធានក្រុមប្រឹក្សាភិបាលធនាគារ អេស៊ីលីដា ឡាវ និងស្ថាប័នមីក្រូហិរញ្ញវត្ថុ អេស៊ីលីដា មីយ៉ាន់ម៉ា ព្រមទាំងជាតំណាងភាគទុនិករបស់ ធនាគារ អេស៊ីលីដា ឡាវ, អេស៊ីលីដា ស៊ីយ្យូរីធី ភីអិលស៊ី, វិទ្យាស្ថាន ពាណិជ្ជសាស្ត្រ អេស៊ីលីដា, ស្ថាប័នមីក្រូហិរញ្ញវត្ថុ អេស៊ីលីដា មីយ៉ាន់ម៉ា, និងអេស៊ីលីដា ប្រូភើធី អិលធីឌី ។

លោកបណ្ឌិត ក៏ជាប្រធានក្រុមប្រឹក្សាភិបាល អេស៊ីលីដាហ្វាយណាន់ហ្សល់ត្រាស់ ។ ក្រៅពីមុខងារ និងតួនាទីនៅក្នុង អេស៊ីលីដា លោកបណ្ឌិត គឺជាប្រធានសមាគមពាណិជ្ជកម្ម និងវិនិយោគកម្ពុជា-ជប៉ុន (ស.ព.វ.ក.ជ) និងជាសមាជិកអនុគណៈកម្មាធិការរាជរដ្ឋាភិបាល សម្រាប់អភិបាលកិច្ចសាជីវកម្ម ។ លោកបណ្ឌិត ជាអ្នកតំណាងធនាគារ អេស៊ីលីដា ភីអិលស៊ី ជាសមាជិករបស់វេទិកាសេដ្ឋកិច្ចពិភពលោក ។

នៅក្នុងឆ្នាំ១៩៩៨ លោកបានបញ្ចប់វគ្គគ្រប់គ្រង ស្តីពីស្ថាប័នហិរញ្ញវត្ថុសម្រាប់អភិវឌ្ឍន៍សហគ្រាសឯកជន (FIPED) ពីសាកលវិទ្យាល័យ Harvard សហរដ្ឋអាមេរិក ។ លោកបានបញ្ចប់ការសិក្សាថ្នាក់បណ្ឌិតផ្នែកគ្រប់គ្រងអាជីវកម្ម និងបានបញ្ចប់វគ្គសិក្សា ស្តីពីអភិបាលក្រុមហ៊ុនពីវិទ្យាស្ថានអូស្ត្រាលី សម្រាប់អភិបាលក្រុមហ៊ុន (GAICD) ។

# ក្រុមប្រឹក្សាភិបាល

សមាជិក-សមាជិកាក្រុមប្រឹក្សាភិបាល ត្រូវតែងតាំងដោយតំណាងភាគទុនិក សម្រាប់អាណត្តិបី(៣)ឆ្នាំ ដើម្បីធ្វើសកម្មភាពតំណាងឱ្យភាគទុនិក ។ តាមលក្ខន្តិកៈបានបញ្ជាក់ថា សមាសភាពក្រុមប្រឹក្សាភិបាល ត្រូវមានយ៉ាងតិចបី(៣)រូប និង ៖

- ក្រុមប្រឹក្សាភិបាល ទទួលខុសត្រូវកំណត់យុទ្ធសាស្ត្ររបស់ វិទ្យាស្ថាន ពាណិជ្ជសាស្ត្រ អេស៊ីលីដា និងដឹកនាំត្រួតពិនិត្យ ដំណើរការកិច្ចការអាជីវកម្ម ។ សមាជិក-សមាជិកា ក្រុមប្រឹក្សាភិបាល ត្រូវធ្វើកិច្ចការណាដែលផ្តល់ផលប្រយោជន៍ខ្ពស់បំផុតដល់ វិទ្យាស្ថាន ពាណិជ្ជសាស្ត្រ អេស៊ីលីដា ។
- អំណាចរបស់ក្រុមប្រឹក្សាភិបាលត្រូវអនុវត្តរួមគ្នា ហើយគ្មានសមាជិក-សមាជិកាក្រុមប្រឹក្សាភិបាលណាម្នាក់ មានអំណាចចាត់ចែងមន្ត្រី ឬនិយោជិតរបស់ វិទ្យាស្ថាន ពាណិជ្ជសាស្ត្រ អេស៊ីលីដា ចុះហត្ថលេខាលើកិច្ចសន្យាណាមួយ ឬចាត់ចែងប្រតិបត្តិការរបស់ វិទ្យាស្ថាន ពាណិជ្ជសាស្ត្រ អេស៊ីលីដា លុះត្រាតែបានទទួលអំណាចពិសេស ដើម្បីចាត់ចែងទៅតាមសេចក្តីសម្រេចរបស់ក្រុមប្រឹក្សាភិបាល ។
- សមាជិក-សមាជិកាក្រុមប្រឹក្សាភិបាលម្នាក់ៗ អាចពិនិត្យមើលដោយគ្មានកម្រិតនូវបញ្ជី ឬរបាយការណ៍របស់ វិទ្យាស្ថាន ពាណិជ្ជសាស្ត្រ អេស៊ីលីដា នៅក្នុងពេលម៉ោងធ្វើការធម្មតា ។

ក្រុមប្រឹក្សាភិបាលទាំងអស់ ត្រូវជ្រើសតាំងក្នុងចំណោមសមាជិក-សមាជិការបស់ខ្លួនមួយ(១)រូប ដើម្បីធ្វើជាប្រធានដោយសម្លេងឆ្នោតគាំទ្រភាគច្រើន ។ ប្រធានក្រុមប្រឹក្សាភិបាល ជាអ្នកដឹកនាំរាល់កិច្ចប្រជុំក្រុមប្រឹក្សាភិបាល។ សម្លេងឆ្នោតគាំទ្រភាគច្រើន នៃសមាជិក-សមាជិកាក្រុមប្រឹក្សាភិបាល ដែលកំពុងបម្រើការងារនៅការិយាល័យអាចផ្លាស់ប្តូរប្រធានក្រុមប្រឹក្សាភិបាលបាន ប៉ុន្តែមិនអាចដកហូតតួនាទីជាសមាជិកសមាជិកាក្រុមប្រឹក្សាភិបាលបានឡើយ ។

សមាជិក-សមាជិកា ក្រុមប្រឹក្សាណាម្នាក់ ដែលមានផលប្រយោជន៍ហិរញ្ញវត្ថុ ទោះផ្ទាល់ ឬដោយប្រយោលក៏ដោយ ឬបើមានសមាជិកក្រុមគ្រួសារផ្ទាល់មានផលប្រយោជន៍បែបនេះ មុនពេលក្រុមប្រឹក្សាភិបាលធ្វើការសម្រេចលើសំណើណាក៏ដោយ សមាជិក-សមាជិកាក្រុមប្រឹក្សារូបនោះ ត្រូវតែជម្រាបសមាជិក-សមាជិកាក្រុមប្រឹក្សាដទៃទៀត ពីផលប្រយោជន៍នោះ មុនពេលអង្គប្រជុំក្រុមប្រឹក្សាភិបាលធ្វើការអនុម័ត ហើយសមាជិក-សមាជិកាក្រុមប្រឹក្សារូបនោះ មិនត្រូវចូលរួមពិភាក្សាលើសំណើនោះទេ លុះត្រាណាតែតម្រូវឱ្យចូលរួមពិភាក្សា ដោយមានសម្លេងឆ្នោតគាំទ្រភាគច្រើន ពីសមាជិក-សមាជិកាក្រុមប្រឹក្សាដទៃទៀត ដែលចូលរួមក្នុងអង្គប្រជុំនោះ ។ សមាជិក-សមាជិកាក្រុមប្រឹក្សារូបនោះមិនត្រូវបោះឆ្នោតលើករណីបែបនោះទេ ប៉ុន្តែវត្តមានរបស់សមាជិក-សមាជិកាក្រុមប្រឹក្សារូបនោះអាចរាប់បញ្ចូលក្នុងកូរ៉ុមនៃអង្គប្រជុំ ។

ក្រុមប្រឹក្សាភិបាលទទួលខុសត្រូវលើអភិបាលកិច្ចសាជីវកម្ម និងការជំរុញអភិវឌ្ឍន៍ជោគជ័យរបស់ វិទ្យាស្ថាន ពាណិជ្ជសាស្ត្រ អេស៊ីលីដា ។ ក្រុមប្រឹក្សាភិបាល ជាអ្នកតែងតាំងនាយកវិទ្យាស្ថាន សម្រាប់ដឹកនាំកិច្ចការវិទ្យាស្ថាន ពាណិជ្ជសាស្ត្រ អេស៊ីលីដា និងអាចដកតំណែង នាយកវិទ្យាស្ថានវិញបាន ។

ក្រុមប្រឹក្សាភិបាលអាចបង្កើតគណៈកម្មាធិការនានា ដែលយល់ថាចាំបាច់ក្នុងការដឹកនាំកិច្ចការជំនួញ និងប្រតិបត្តិការរបស់ វិទ្យាស្ថាន ពាណិជ្ជសាស្ត្រ អេស៊ីលីដា ។ គណៈកម្មាធិការទាំងនេះ បង្កើតឡើងតាមឆន្ទៈរបស់ក្រុមប្រឹក្សាភិបាល ហើយសមាជិក-សមាជិកាទាំងអស់ នៃ គណៈកម្មាធិការទាំងនេះ ត្រូវតែអនុវត្តទៅតាមឆន្ទៈរបស់ ក្រុមប្រឹក្សាភិបាល ។



ក្រុមប្រឹក្សាភិបាល វិទ្យាស្ថាន ពាណិជ្ជសាស្ត្រ អេស៊ីលីដា

## បណ្ឌិត សូ ផនណារី

ប្រធានក្រុមប្រឹក្សាភិបាល



ជនជាតិខ្មែរ កើតក្នុងខែវិច្ឆិកា ឆ្នាំ១៩៦៣ ។ លោកស្រីបានបញ្ចប់ថ្នាក់បណ្ឌិត ផ្នែកគ្រប់គ្រងធុរកិច្ច និងបានចូលបម្រើការនៅអេស៊ីលីដា ចាប់តាំងពីថ្ងៃទី១៨ ខែសីហា ឆ្នាំ១៩៩៣ ។

ក្នុងមុខតំណែងជា អនុប្រធាននាយកប្រតិបត្តិ និងជាគណៈប្រធាននាយិកាប្រតិបត្តិប្រតិបត្តិការ លោកស្រីបណ្ឌិត ក៏ជាសមាជិកាគណៈកម្មាធិការប្រតិបត្តិ ទទួលបន្ទុកដឹកនាំលើប្រតិបត្តិការរបស់ធនាគារ និង គ្រប់គ្រងនាយកដ្ឋានប្រតិបត្តិការ, នាយកដ្ឋានទីផ្សារ, នាយកដ្ឋានអភិវឌ្ឍន៍ផលិតផល, នាយកដ្ឋានឥណទាន, នាយកដ្ឋានសេវាឥណទាន និងហិរញ្ញប្បទានពាណិជ្ជកម្ម, និងនាយកដ្ឋានសេវាហិរញ្ញវត្ថុ ។ លោកស្រីបណ្ឌិត ទទួលបន្ទុកគ្រប់គ្រងផែនការយុទ្ធសាស្ត្រ និងប្រតិបត្តិការអាជីវកម្មប្រចាំថ្ងៃរបស់ធនាគារ ដោយផ្តោត ទៅលើផែនការយុទ្ធសាស្ត្រលក់ផលិតផល និងសេវាកម្មដែលមានស្រាប់ និងថ្មីៗ ។ លោកស្រីបណ្ឌិត ទទួលខុសត្រូវទៅលើការដឹកនាំ ត្រួតពិនិត្យ និងវាយតម្លៃ លើប្រតិបត្តិការអាជីវកម្មប្រចាំថ្ងៃរបស់ធនាគារ ។ លើសពីនេះលោកស្រីបណ្ឌិតក៏ជាសមាជិកាណៈកម្មាធិការគ្រប់គ្រងទ្រព្យសកម្ម និងអកម្ម, គណៈកម្មាធិការ កំណត់ថ្លៃផលិតផល និងសេវាកម្ម, និងគណៈកម្មាធិការឥណទាន នៃថ្នាក់គ្រប់គ្រង ។ លោកស្រីបណ្ឌិត ទទួលខុសត្រូវចំពោះប្រធាននាយកប្រតិបត្តិ ។

ទំនួលខុសត្រូវផ្សេងទៀតរបស់លោកស្រីបណ្ឌិត ជាប្រធានក្រុមប្រឹក្សាភិបាល របស់វិទ្យាស្ថាន ពាណិជ្ជសាស្ត្រ អេស៊ីលីដា ។

## លោក ព្រំ ទិសុទ្ធ

អភិបាល



ជនជាតិខ្មែរ កើតនៅថ្ងៃទី១១ ខែមករា ឆ្នាំ១៩៧៥។ លោកទទួលបាន អនុបណ្ឌិតគ្រប់គ្រងអាជីវកម្ម ជំនាញហិរញ្ញវត្ថុ ពីសាកលវិទ្យាល័យ Charles Sturt ប្រទេសអូស្ត្រាលី។

លោកបានបម្រើការនៅ ធនាគារ អេស៊ីលីដា ចាប់តាំងពីខែមិថុនា ឆ្នាំ១៩៩៨ ក្នុងមុខតំណែងជាគណនេយ្យករ បន្ទាប់មកជា ប្រធានផ្នែកត្រួតពិនិត្យឥណទាន បន្ទាប់មកទៀតជា នាយកសាខា ក្រោយមកជា ប្រធានក្រុម កិច្ចការច្បាប់និងលេខាធិការក្រុមហ៊ុន ក្រោយមកទៀតជា នាយកប្រតិបត្តិនីតិកម្មនិងលេខាធិការក្រុមហ៊ុន និងតំណែង ចុងក្រោយជា អនុប្រធាននាយកប្រតិបត្តិនិង ជាគណៈប្រធាននាយកប្រតិបត្តិនីតិកម្មនិងលេខាធិការ ក្រុមហ៊ុន។ ការទទួលខុសផ្សេងៗទៀតក្នុងក្រុមហ៊ុនបុត្រសម្ព័ន្ធ លោកជាសមាជិកក្រុមប្រឹក្សាភិបាល វិទ្យាស្ថាន ពាណិជ្ជសាស្ត្រ អេស៊ីលីដា និងអេស៊ីលីដា ស៊ីយូរីធី ភីអិលស៊ី និងជាប្រធានក្រុមប្រឹក្សាភិបាល អេស៊ីលីដា ប្រូភើធី អិលធីឌី។ លោកត្រូវបានតែងតាំងជា អគ្គនាយក អេស៊ីលីដា ស៊ីយូរីធី ភីអិលស៊ី ពីថ្ងៃទី០១ ខែវិច្ឆិកា ឆ្នាំ២០១៧។

## បណ្ឌិត ឡឹង សុភាព

អភិបាល



ជនជាតិខ្មែរកើតក្នុងខែមីនាឆ្នាំ១៩៦៧។ បណ្ឌិត ឡឹង សុភាព បានបញ្ចប់ថ្នាក់បណ្ឌិតផ្នែកគ្រប់គ្រង ពាណិជ្ជកម្ម ពីសាកលវិទ្យាល័យ Preston រាជធានីភ្នំពេញ ព្រះរាជាណាចក្រកម្ពុជា ក្នុងឆ្នាំ២០១២។

លោកបានចូលបម្រើការងារជាមួយ ធនាគារ អេស៊ីលីដា ភីអិលស៊ី ចាប់តាំង ពីខែធ្នូ ឆ្នាំ១៩៩៧ ជា គណនេយ្យករ។ ចាប់ពីពេលនោះមក លោកទទួលមុខងារនិងតួនាទីផ្សេងៗជាច្រើន នៅក្នុងធនាគារ។ បច្ចុប្បន្ន ក្នុងតួនាទីជាអនុប្រធាននាយកប្រតិបត្តិ និងជាគណៈប្រធាននាយកប្រតិបត្តិហានិភ័យ លោកទទួលខុសត្រូវ គ្រប់គ្រងហានិភ័យឥណទាន និងហានិភ័យផ្សេងៗទៀត របស់ធនាគារទាំងមូល។ លោកត្រូវបានតែងតាំង ជាសមាជិកក្រុមប្រឹក្សាភិបាល របស់ អេស៊ីលីដា ស៊ីយូរីធី ភីអិលស៊ី និងជាសមាជិកក្រុមប្រឹក្សាភិបាល របស់ វិទ្យាស្ថាន ពាណិជ្ជសាស្ត្រ អេស៊ីលីដា ចាប់តាំងពី ខែកក្កដា ឆ្នាំ២០១៧។

## លោក Pieter Kooi
អភិបាល



ជនជាតិហុល្លង់ដ៍ កើតក្នុងឆ្នាំ១៩៥៨ បានចូលរួមក្នុងក្រុមប្រឹក្សាភិបាលរបស់ វិទ្យាស្ថាន ពាណិជ្ជសាស្ត្រ អេស៊ីលីដា នៅក្នុងខែមករា ឆ្នាំ២០១៦ និងត្រូវបានតែងតាំងជាប្រធានគណៈកម្មាធិការសវនកម្ម សីលធម៌ និងសម្របសម្រួលកិច្ចការច្បាប់ នៃក្រុមប្រឹក្សាភិបាលនៅក្នុងខែកញ្ញា ឆ្នាំ២០១៦។ លោកទទួលបាន អនុបណ្ឌិតផ្នែកហិរញ្ញវត្ថុសាជីវកម្ម និងសង្គមវិទ្យា នៅសាកលវិទ្យាល័យ Erasmus ក្នុងទីក្រុង Rotterdam ប្រទេសហុល្លង់ដ៍ ។ ចាប់ពីឆ្នាំ១៩៩៣ លោកបានធ្វើជាទីប្រឹក្សាមីក្រូហិរញ្ញវត្ថុឱ្យអេស៊ីលីដា រយៈពេលជាង ៧ឆ្នាំ ដើម្បីកម្លាយខ្លួនពីកម្មវិធីអភិវឌ្ឍន៍ទៅជាធនាគារពាណិជ្ជ ។ ចាប់ពីឆ្នាំ១៩៩៩ បណ្ឌិត Pieter KOOI បាន បម្រើការងារជាទីប្រឹក្សាមីក្រូហិរញ្ញវត្ថុ រយៈពេលខ្លី ដល់ស្ថាប័នមីក្រូហិរញ្ញវត្ថុ នៅក្នុង ១៥ប្រទេស ដែល ភាគច្រើនស្ថិតក្នុងទ្វីបអាហ្វ្រិក និងអាស៊ី ។

បណ្ឌិត Pieter KOOI បានចូលជាក្រុមប្រឹក្សាភិបាលនៃធនាគារ អេស៊ីលីដា ភីអិលស៊ី នៅក្នុងខែតុលា ឆ្នាំ២០០០។ ចាប់ពីខែកញ្ញា ឆ្នាំ២០០២ ដល់ខែធ្នូ ឆ្នាំ២០០៥ លោកមានតួនាទីជានាយកផ្នែកមីក្រូហិរញ្ញវត្ថុ របស់ UNCDF ក្នុងទីក្រុងញូវយ៉ក ។ ចាប់ពីខែមីនា ឆ្នាំ២០០៦ រហូតដល់ខែឧសភា ឆ្នាំ២០១១ លោក បានធ្វើជាទីប្រឹក្សាក្រៅម៉ោងឱ្យធនាគារ អេស៊ីលីដា ភីអិលស៊ី ក្នុងការបង្កើតធនាគារ អេស៊ីលីដា ឡាវ, អេស៊ីលីដា ត្រេននីង សេនធ័រ, និងអេស៊ីលីដា ស៊ីឃ្យូរីធី ។ បច្ចុប្បន្នលោកធ្វើជាក្រុមប្រឹក្សាភិបាលនៅក្នុង ស្ថាប័នជាច្រើន និងផ្តល់ការប្រឹក្សារយៈពេលខ្លី ហើយថែមទាំងបង្ហាត់បង្រៀនអំពីមីក្រូហិរញ្ញវត្ថុ អភិបាលកិច្ច និងយុទ្ធសាស្ត្រគ្រប់គ្រង ។ លោកបានបញ្ចប់ការសិក្សាពីវិទ្យាស្ថានអូស្ត្រាលីសម្រាប់អភិបាលក្រុមហ៊ុន។

## លោក ឆន ពន្លឺ
អភិបាល



ជនជាតិខ្មែរកើតក្នុងឆ្នាំ១៩៧៨,លោកបានបញ្ចប់ថ្នាក់អនុបណ្ឌិតគ្រប់គ្រងពាណិជ្ជកម្មជំនាញគ្រប់គ្រងពី សាកលវិទ្យាល័យជាតិគ្រប់គ្រង នៅក្នុងឆ្នាំ២០០៥ ។ នៅក្នុងឆ្នាំ១៩៩៩ លោកបានបញ្ចប់ថ្នាក់បរិញ្ញាបត្រ គ្រប់គ្រងពាណិជ្ជកម្មជំនាញទីផ្សារ ពីមហាវិទ្យាល័យពាណិជ្ជសាស្ត្រ ដែលសហការកម្មវិធីសិក្សាជាមួយ University of San Francisco និង Georgetown University ។លោកបានចូលបម្រើការជាមួយ អេស៊ីលីដា នៅក្នុង ខែវិច្ឆិកា ឆ្នាំ១៩៩៩ ។ ចាប់ពីឆ្នាំ២០០៣ មកលោកបានចូលរួមវគ្គបណ្តុះបណ្តាលជាច្រើនទៀត ទាំងនៅក្នុងប្រទេស និងពីបណ្តាប្រទេសមួយចំនួន ទាក់ទងនឹងការបណ្តុះបណ្តាលធនាគារនិងហិរញ្ញវត្ថុ, ការគ្រប់គ្រង និងអភិវឌ្ឍន៍កម្មវិធីបណ្តុះបណ្តាល។ លោកបានបំពេញទស្សនកិច្ចសិក្សា នៅសាកលវិទ្យាល័យ មួយចំនួននៃកោះតៃវ៉ាន់, Harvard Business School នៃសហរដ្ឋអាមេរិក Frankfurt School of Finance and Management នៃប្រទេសអាល្លឺម៉ង់ លើប្រធានបទមួយចំនួនពាក់ព័ន្ធនឹងការគ្រប់គ្រង និងការអភិវឌ្ឍ ខ្លួនទៅជាសាលាពាណិជ្ជសាស្ត្រខ្នាតអន្តរជាតិ។ នៅក្នុងឆ្នាំ២០១៦ លោកបានបញ្ចប់វគ្គបណ្តុះបណ្តាលខ្នាត អន្តរជាតិលើកទី៣៦ នៅប្រទេសអ៊ីស្រាអ៊ែល សម្រាប់ការគ្រប់គ្រងគ្រឹះស្ថានឧត្តមសិក្សាដែលរៀបចំដោយ វិទ្យាស្ថានគ្រប់គ្រងអន្តរជាតិកាលីទ្បេ ។

លោកបានទទួលមុខតំណែងជា អគ្គនាយក អេស៊ីលីដា ត្រេននីង សេនធ័រ ក្នុងឆ្នាំ២០១១ ។ នាពេល បច្ចុប្បន្ននេះ លោកមានតួនាទីជា នាយកវិទ្យាស្ថាន ពាណិជ្ជសាស្ត្រ អេស៊ីលីដា ។ លោកបានក្លាយជា សមាជិកក្រុមប្រឹក្សាភិបាល នៃវិទ្យាស្ថាន ពាណិជ្ជសាស្ត្រ អេស៊ីលីដា នៅខែតុលា ឆ្នាំ២០១៦ ។ ក្រៅពីនេះ លោកគឺជាតំណាងភាគទុនិក របស់អេស៊ីលីដា ត្រេននីង សេនធ័រ នៅក្នុងធនាគារ អេស៊ីលីដាឡាវ លីមីធីត ចាប់ពីឆ្នាំ២០១៣ រហូតមកដល់បច្ចុប្បន្ន ។

# គណៈកម្មាធិការប្រតិបត្តិ

នាយកវិទ្យាស្ថាន ត្រូវបានតែងតាំងឡើងដោយ ក្រុមប្រឹក្សាភិបាល ដើម្បីទទួលខុសត្រូវលើការគ្រប់គ្រងដំណើរការអាជីវកម្មប្រចាំថ្ងៃ របស់វិទ្យាស្ថាន ពាណិជ្ជសាស្ត្រ អេស៊ីលីដា នៅក្នុងរង្វង់គោលការណ៍ និង យុទ្ធសាស្ត្រ ដែលបានអនុម័តដោយក្រុមប្រឹក្សាភិបាល ។ ប៉ុន្តែកិច្ចការជាក់លាក់មួយចំនួន អាចត្រូវបានកំណត់ដោយក្រុមប្រឹក្សាភិបាល ។

នាយកវិទ្យាស្ថាន ជាអ្នកតែងតាំង និងដឹកនាំគណៈកម្មាធិការប្រតិបត្តិ ដែលរួមមានសមាសភាពនៃថ្នាក់ដឹកនាំជាន់ខ្ពស់ ដោយលោកយល់ឃើញថាសមស្រប (ករណីមានការផ្លាស់ប្តូរណាមួយ ត្រូវជូនដំណឹងទៅ ក្រុមប្រឹក្សាភិបាល ឱ្យបានទាន់ពេលសមស្រប) ។ ភារកិច្ចទទួលខុសត្រូវ និងដំណើរការនៃគណៈកម្មាធិការប្រតិបត្តិ នឹងត្រូវកំណត់ដោយនាយកវិទ្យាស្ថាន តាមការសម្រេចក្រោមចំណុចសំខាន់ៗ ទូទៅដូចជា ៖

- ទិសដៅយុទ្ធសាស្ត្រ៖ អភិវឌ្ឍន៍គោលការណ៍ គោលដៅយុទ្ធសាស្ត្រ និងទិសដៅ សម្រាប់ក្រុមប្រឹក្សាភិបាលអនុម័ត ។
- ការអនុវត្ត ៖ ប្រមូលផ្តុំនូវរាល់ធនធាន ដើម្បីអនុវត្តតាមយុទ្ធសាស្ត្រ ដែលបានកំណត់ និងការប្រតិបត្តិតាមគោលដៅ ដែលបានអនុម័ត ។
- ហានិភ័យ ៖ កំណត់ និងវាយតម្លៃលើហានិភ័យ នៅក្នុងយុទ្ធសាស្ត្ររបស់ វិទ្យាស្ថាន ពាណិជ្ជសាស្ត្រ អេស៊ីលីដា និងចាត់ចែងបញ្ហាដែលកើតឡើង ។
- ការប្រតិបត្តិ ៖ ធានាថា វិទ្យាស្ថាន ពាណិជ្ជសាស្ត្រ អេស៊ីលីដា ប្រតិបត្តិ អនុលោមទៅតាមតម្រូវការរបស់ សាជីវកម្ម ច្បាប់ និងបទប្បញ្ញត្តិទាំងអស់ ។

**លោក ឆន ពន្លឺ** នាយកវិទ្យាស្ថាន



ជនជាតិខ្មែរ កើតក្នុងឆ្នាំ១៩៧៨, លោកបានបញ្ចប់ថ្នាក់អនុបណ្ឌិតគ្រប់គ្រងពាណិជ្ជកម្ម ជំនាញគ្រប់គ្រងពីសាកលវិទ្យាល័យជាតិគ្រប់គ្រង នៅក្នុងឆ្នាំ២០០៥ ។ នៅក្នុងឆ្នាំ១៩៩៩ លោកបានបញ្ចប់ថ្នាក់បរិញ្ញាបត្រគ្រប់គ្រងពាណិជ្ជកម្ម ជំនាញទីផ្សារ ពីមហាវិទ្យាល័យពាណិជ្ជសាស្ត្រ ដែលសហការកម្មវិធីសិក្សាជាមួយ University of San Francisco និង Georgetown University ។

ចាប់ពីឆ្នាំ២០០៣ មកលោកបានបំពេញទស្សនកិច្ច និងចូលរួមវគ្គបណ្តុះបណ្តាលជាច្រើន ទាំងនៅក្នុងប្រទេសនិងពីបណ្តាប្រទេសមួយចំនួន ទាក់ទងនឹងការបណ្តុះបណ្តាលធនាគារនិងហិរញ្ញវត្ថុ, ការគ្រប់គ្រងកម្មវិធីបណ្តុះបណ្តាល, វគ្គបណ្តុះបណ្តាលជំនាញរៀបចំនិងអភិវឌ្ឍន៍កម្មវិធីសិក្សា, វគ្គបណ្តុះបណ្តាលគ្រូហ្វឹកហ្វឺន, វគ្គប្រឹក្សាយោបល់បែបវិជ្ជាជីវៈ និងវគ្គបណ្តុះបណ្តាលជាច្រើនផ្សេងទៀត។ លោកបានបំពេញទស្សនកិច្ចសិក្សានៅសាកលវិទ្យាល័យមួយចំនួន នៃកោះតៃវ៉ាន់, Harvard Business School នៃសហរដ្ឋអាមេរិក Frankfurt School of Finance and Management នៃប្រទេស អាល្លឺម៉ង់ លើប្រធានបទមួយចំនួនពាក់ព័ន្ធនឹងការគ្រប់គ្រង និងការអភិវឌ្ឍខ្លួនទៅជាសាលាពាណិជ្ជសាស្ត្រខ្នាតអន្តរជាតិ។ នៅក្នុងឆ្នាំ២០១៦ លោកបានបញ្ចប់វគ្គបណ្តុះបណ្តាលខ្នាតអន្តរជាតិលើកទី៣៦ នៅប្រទេសអ៊ីស្រាអ៊ែលសម្រាប់ការគ្រប់គ្រងគ្រឹះស្ថានឧត្តមសិក្សា ដែលរៀបចំដោយវិទ្យាស្ថានគ្រប់គ្រងអន្តរជាតិកាលីឡេ ។

លោកបានចូលបម្រើការជាមួយ អេស៊ីលីដា មីក្រូហិរញ្ញវត្ថុ នៅក្នុងខែវិច្ឆិកា ឆ្នាំ១៩៩៩ ក្នុងមុខតំណែងជាគណនេយ្យករ និងត្រូវបានដំឡើងមុខងារតួនាទីទៅជា ប្រធានគណនេយ្យករសាខា នៅក្នុងខែកុម្ភៈឆ្នាំ២០០០។ជាបន្តនៅក្នុងខែកុម្ភៈឆ្នាំ២០០៥លោកត្រូវបានផ្លាស់ប្តូរមុខងារតួនាទីទៅជាប្រធានទីផ្សារសាខា និងត្រូវបានដំឡើងមុខងារតួនាទីជា នាយកសាខា ធនាគារ អេស៊ីលីដា ភីអិលស៊ី នៅក្នុងឆ្នាំ២០០៧ និងត្រូវបានផ្លាស់ប្តូរមុខតំណែងជា នាយកការិយាល័យបណ្តុះបណ្តាលមីក្រូហិរញ្ញវត្ថុ អេស៊ីលីដា-អាស៊ាន នៅក្នុងឆ្នាំ២០០៩។ នាខែសីហា ឆ្នាំ២០១១ លោកបានទទួលមុខតំណែងជាអគ្គនាយក អេស៊ីលីដា ត្រេននីង សេនធ័រ ។ នាពេលបច្ចុប្បន្ននេះ លោកមានតួនាទីជា នាយកវិទ្យាស្ថាន និងជាសមាជិកអចិន្ត្រៃយ៍នៃក្រុមប្រឹក្សាភិបាល វិទ្យាស្ថាន ពាណិជ្ជសាស្ត្រ អេស៊ីលីដា ។ ក្រៅពីនេះ លោកគឺជា តំណាងភាគទុនិករបស់ អេស៊ីលីដា ត្រេននីង សេនធ័រ នៅក្នុងធនាគារ អេស៊ីលីដាឡាវ លីមីធីត ចាប់ពីឆ្នាំ ២០១៣ រហូតមកដល់បច្ចុប្បន្ន ។



**លោក ហុង ហោម្ធលី** នាយករង និងជាប្រធានការិយាល័យផែនការ និងហិរញ្ញវត្ថុ

លោក ជាជនជាតិខ្មែរ កើតនៅឆ្នាំ១៩៨០ ក្នុងខេត្តកំពង់ឆ្នាំង។ លោកបានបញ្ចប់ថ្នាក់បរិញ្ញាបត្រជាន់ខ្ពស់ផ្នែកហិរញ្ញវត្ថុ ពីសាកលវិទ្យាល័យជាតិគ្រប់គ្រង ។ លោកបានបញ្ចប់ថ្នាក់បរិញ្ញាបត្រច្បាប់ពីសាកលវិទ្យាល័យភូមិន្ទនីតិសាស្ត្រ និងវិទ្យាសាស្ត្រសេដ្ឋកិច្ច នៅក្នុងឆ្នាំ២០០២ និងបរិញ្ញាបត្រគ្រប់គ្រងពាណិជ្ជកម្ម ជំនាញគណនេយ្យពីវិទ្យាស្ថានជាតិគ្រប់គ្រងនៅក្នុងឆ្នាំ២០០៣។ បច្ចុប្បន្ន លោកកំពុងបន្តសិក្សា ថ្នាក់គណនេយ្យជំនាញ ACCA ។ លោកធ្លាប់បានចូលរួមវគ្គហ្វឹកហ្វឺនជាច្រើន ទាក់ទងទៅនឹងវិស័យហិរញ្ញវត្ថុ និងធនាគារ ការគ្រប់គ្រងនិងដឹកនាំ វគ្គហ្វឹកហ្វឺនគ្រូបង្រៀន វគ្គសវនកម្មរបាយការណ៍ហិរញ្ញវត្ថុ វគ្គស៊ើបអង្កេត និងការពារការក្លែងបន្លំ ។ល។

លោកបានចូលបម្រើការងារជាមួយធនាគារ អេស៊ីលីដា ភីអិលស៊ី នៅក្នុងឆ្នាំ២០០៣ ក្នុងមុខតំណែងជាគណនេយ្យករសាខា ហើយត្រូវបានដំឡើងមុខងារជាអនុប្រធានគណនេយ្យករសាខា នៅក្នុង ឆ្នាំ២០០៥ ។ នៅក្នុងឆ្នាំ២០០៨ លោកត្រូវបានតែងតាំងជា អនុប្រធានផ្នែក សវនកម្មសេវាធនាគារអេឡិចត្រូនិច និងសេវាហិរញ្ញប្បទានពាណិជ្ជកម្ម នៃធនាគារ អេស៊ីលីដា ភីអិលស៊ី ការិយាល័យកណ្តាល និង នៅឆ្នាំ២០០៩ ត្រូវបានតែងតាំងជាជំនួយការនាយិកាប្រតិបត្តិសវនកម្ម និង នៅឆ្នាំ២០១២ លោកត្រូវបានតែងតាំងជានាយកការិយាល័យសវនកម្មហិរញ្ញវត្ថុ។ នៅក្នុងឆ្នាំ២០១៦ លោកត្រូវបានផ្លាស់ប្តូរមុខងារជា នាយករង និងជា ប្រធានការិយាល័យផែនការនិងហិរញ្ញវត្ថុ នៃ វិទ្យាស្ថាន ពាណិជ្ជសាស្ត្រ អេស៊ីលីដា។



**លោក ហាស់ សម្បត្តិ** ប្រធានការិយាល័យបុគ្គលិក និងរដ្ឋបាល

ជនជាតិខ្មែរ កើតឆ្នាំ១៩៥៩ ។ លោកបានទទួល សញ្ញាបត្រភាសាអង់គ្លេស ពី Gwynedd-Mercy College (USA) ក្នុងឆ្នាំ១៩៨៧ ។ លោកក៏បានចូលរួមវគ្គបណ្តុះបណ្តាល ជំនាញគ្រប់គ្រងឥណទាន និងការដោះស្រាយបំណុល ជាមួយ Mekong Project Development Facility (MPDF) នៅក្នុងឆ្នាំ ២០០២ ។ នៅឆ្នាំ១៩៩៥ លោកបានចូលរួម វគ្គបណ្តុះបណ្តាលជំនាញទីផ្សារ ជាមួយ Care International នៅប្រទេសថៃ និងបានចូលរួមវគ្គបណ្តុះបណ្តាល Micro Banking System ជាមួយ ធនាគារ RAKYAT (BRI) នៅប្រទេសឥណ្ឌូណេស៊ី ក្នុងឆ្នាំ១៩៩៨ ។ ចាប់ពី ឆ្នាំ១៩៩៤ មក លោកបានចូលរួមវគ្គបណ្តុះបណ្តាលផ្សេងៗ ជាច្រើនទៀត ទាំងនៅក្នុងប្រទេស និងក្រៅប្រទេស។

លោកបានចូលបម្រើការងារជាមួយ អេស៊ីលីដា នៅថ្ងៃទី០១ ខែកក្កដា ឆ្នាំ១៩៩៤ ក្នុងតួនាទី ជាមន្ត្រី ឥណទាន ហើយលោកត្រូវបានតែងតាំងជាប្រធានការិយាល័យស្រុកនៅឆ្នាំ១៩៩៧ ។

នៅក្នុងឆ្នាំ ១៩៩៨ លោកត្រូវបានតែងតាំងជា នាយករងសាខា និងត្រូវបានតែងតាំងជានាយកសាខា ក្នុងឆ្នាំ២០០១ ។ នៅឆ្នាំ២០០៨ លោកត្រូវ បានតែងតាំងជា នាយកការិយាល័យគ្រប់គ្រង ការិយាល័យកណ្តាល។ នៅក្នុងឆ្នាំ២០១០ លោកត្រូវបានផ្លាស់មុខងារតួនាទី ទៅជានាយករងនាយកដ្ឋានរដ្ឋបាល ។ ចាប់ពីខែកុម្ភៈ ឆ្នាំ២០១៣ មកដល់ថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០១៣ លោកមានតួនាទីជា នាយកការិយាល័យហិរញ្ញវត្ថុ និង រដ្ឋបាល នៃ អេស៊ីលីដា ត្រេននីង សេនធ័រ ។ ចាប់ពីថ្ងៃទី០១ ខែមករា ឆ្នាំ២០១៤ ដល់ ថ្ងៃទី ៣១ ខែមករាឆ្នាំ ២០១៦ លោកមានតួនាទីជានាយកការិយាល័យបុគ្គលិក និងរដ្ឋបាល នៃអេស៊ីលីដា ត្រេននីង សេនធ័រ ។ ចាប់ពីខែកុម្ភៈ ឆ្នាំ២០១៦ មកដល់បច្ចុប្បន្ន លោកមានតួនាទីជា ប្រធានការិយាល័យបុគ្គលិក និងរដ្ឋបាល នៃវិទ្យាស្ថាន ពាណិជ្ជសាស្ត្រ អេស៊ីលីដា ។



**លោក សូ សុវណ្ណារ៉េត** ប្រធានមជ្ឈមណ្ឌលហ្វឹកហ្វឺន

កើតខែមិថុនា ឆ្នាំ១៩៧៣, លោកបានទទួលសញ្ញាបត្រថ្នាក់អនុបណ្ឌិត គ្រប់គ្រងអភិវឌ្ឍន៍ (MDM) ជំនាញគ្រប់គ្រង ពីសាកលវិទ្យាល័យន័រតុន នៅឆ្នាំ២០០៨ ។ លោកបានបញ្ចប់បរិញ្ញាបត្រផ្នែកគ្រប់គ្រង ជំនាញគ្រប់គ្រង ពីវិទ្យាស្ថាន វិទ្យាសាស្ត្រគ្រប់គ្រង នៅឆ្នាំ២០០៤ និងសញ្ញាបត្រភាសាអង់គ្លេស ផ្នែកទំនាក់ទំនងពាណិជ្ជកម្ម ពីវិទ្យាស្ថានអប់រំពាណិជ្ជសាស្ត្រ (Institute for Business Education) ក្នុងឆ្នាំ២០១០ ។ នៅឆ្នាំ២០១៥ លោកទទួលបាន សញ្ញាបត្រ Certified Expert in Risk Management ពីសាលា Frankfurt School of Finance and Management ប្រទេសអាល្លឺម៉ង់។ នៅក្នុងឆ្នាំ២០១១, លោកបានបញ្ចប់ វគ្គបណ្តុះបណ្តាលការគ្រប់គ្រង គ្រឹះស្ថានមីក្រូហិរញ្ញវត្ថុ នៅទីក្រុង Frankfurt ប្រទេសអាល្លឺម៉ង់ និង វគ្គបណ្តុះបណ្តាលគ្រូហ្វឹកហ្វឺន, វគ្គជំនាញរៀបចំនិងអភិវឌ្ឍន៍កម្មវិធីសិក្សា, និងវគ្គជំនាញប្រឹក្សាយោបល់បែបវិជ្ជាជីវៈ ជាមួយសាលា Robenny School of Business នៅប្រទេសចិន និងនៅទីក្រុងហុងកុង ។ ចាប់ពីឆ្នាំ១៩៩៤ លោកក៏បានចូលរួមវគ្គបណ្តុះបណ្តាលជាច្រើនទៀតទាំងក្នុងប្រទេស និងក្រៅប្រទេស ដូចជាៈ ជំនាញគ្រប់គ្រងឥណទាននិងការដោះស្រាយបំណុលជាមួយ MPDF, ជំនាញទីផ្សារជាមួយ CARE International នៅប្រទេសថៃ, វគ្គ Micro Banking System ជាមួយធនាគារ RAKYAT(BRI) នៅប្រទេសឥណ្ឌូនេស៊ី, វគ្គជំនាញភ្នាក់ងារឥណទាន, វគ្គគ្រប់គ្រងសម្រាប់នាយករង និងប្រធាន ការិយាល័យស្រុក, វគ្គ Coaching for Success & Leadership Effectiveness. និងវគ្គ Advanced Training and Capacity Building Strategies និងវគ្គ Specialized MFISV Program on Training Management ។

លោកបានចូលបម្រើការងារជាមួយ អេស៊ីលីដា នៅឆ្នាំ១៩៩៤ ក្នុងតួនាទីជា មន្ត្រីឥណទាន និងមន្ត្រី ទំនាក់ទំនងរវាងអង្គការពលកម្មអន្តរជាតិ និងអេស៊ីលីដា ហើយលោកត្រូវបានតែងតាំងជា ប្រធានការិយាល័យស្រុក នៅ ឆ្នាំ១៩៩៧ ។ លោកត្រូវបានតែងតាំង ជាប្រធានផ្នែកហ្វឹកហ្វឺន នៅឆ្នាំ ២០០៥ ដល់ខែមិថុនា ឆ្នាំ២០០៩ ហើយបន្ទាប់មក លោកក៏ត្រូវបានដំឡើងឋានៈ ជាជំនួយការនាយកប្រតិបត្តិហ្វឹកហ្វឺន នៅខែកក្កដា ឆ្នាំ២០០៩, និងត្រូវបានតែងតាំងជានាយកការិយាល័យសិក្សា ចាប់ពី ខែសីហា ឆ្នាំ២០១១ ដល់ ខែធ្នូ ឆ្នាំ២០១២, ហើយចាប់ពីខែមករា ឆ្នាំ ២០១៣ ដល់ ខែ កុម្ភៈ ឆ្នាំ ២០១៦ លោកត្រូវបានតែងតាំងជា នាយកការិយាល័យស្រាវជ្រាវ និងអភិវឌ្ឍន៍ ។ នាពេលបច្ចុប្បន្ននេះ លោកមានតួនាទីជាប្រធានមជ្ឈមណ្ឌលហ្វឹកហ្វឺន ។

## លោកស្រី ឱុត សុវណ្ណា ប្រធានការិយាល័យសិក្សា និងកិច្ចការនិស្សិត



កើតក្នុងឆ្នាំ១៩៨០ សុវណ្ណា បានបញ្ចប់ថ្នាក់អនុបណ្ឌិតគ្រប់គ្រងពាណិជ្ជកម្ម ជំនាញគ្រប់គ្រង ពីសាកលវិទ្យាល័យ បញ្ញាសាស្ត្រ នៅក្នុងឆ្នាំ ២០១៤។ លោកស្រីបានបញ្ចប់ថ្នាក់បរិញ្ញាបត្រអក្សរសាស្ត្រអង់គ្លេស ជំនាញអប់រំ ពីសាកលវិទ្យាល័យនរតុន នៅក្នុងឆ្នាំ២០០២ ។

នៅក្នុងឆ្នាំ ២០០៩ លោកស្រីបានចូលរួមវគ្គទស្សនកិច្ចសិក្សា លើប្រធានបទ ការគ្រប់គ្រងការហ្វឹកហ្វឺន នៅ CARD MRI ប្រទេសហ្វីលីពីន, វគ្គហ្វឹកហ្វឺនលើប្រធានបទ ការគ្រប់គ្រងទីផ្សារ នៅ AMiDA (Academy for Microfinance Development in Asia) បាលី ប្រទេសឥណ្ឌូណេស៊ី, វគ្គហ្វឹកហ្វឺនលើប្រធានបទការអភិវឌ្ឍលើជំនាញវិជ្ជាជីវៈ ជាមួយ Robenny School of Business នៅប្រទេសវៀតណាម, និង វគ្គហ្វឹកហ្វឺនលើប្រធានបទការបណ្តុះបណ្តាល គ្រូបង្រៀន ជាមួយ Frankfurt School of Finance & Management និងជាមួយ Center for Microfinance Leadership Women's World Banking ភ្នំពេញ ព្រះរាជាណាចក្រកម្ពុជា ។

នៅក្នុងឆ្នាំ ២០១៤ លោកស្រីបា នចូលរួមវគ្គទស្សនកិច្ចសិក្សាទៅសាកលវិទ្យាល័យដែលល្បីៗ នៅ តៃវ៉ាន់ ដើម្បីសិក្សាអំពីប្រព័ន្ធអប់រំរបស់សាកលវិទ្យាល័យនីមួយៗ ទាក់ទងនឹងការគ្រប់គ្រងនិស្សិត និងបណ្ណាល័យ។

នៅក្នុងឆ្នាំ ២០១៧ លោកស្រីបានចូលរួមវគ្គទស្សនកិច្ចសិក្សានៅ Ross School of Business,William Davidson Institute, at the University of Michigan in Ann Arbor, នៅសហរដ្ឋអាមេរិក លើប្រធានបទ ស្តីពីការបង្កើនសមត្ថភាពអេស៊ីលីដា ទៅជាវិទ្យាស្ថានធុរកិច្ច ដែលឈានមុខគេ នៅក្នុងប្រទេសកម្ពុជា ។

នៅក្នុងខែមីនា ឆ្នាំ២០០៤ លោកស្រីបានចូលបម្រើការក្នុងផ្នែកហ្វឹកហ្វឺននៃធនាគារ អេស៊ីលីដា ភីអិលស៊ី នៅឆ្នាំ២០០៨ លោកស្រីត្រូវបានតែងតាំងជា អនុប្រធានផ្នែកកម្មសិក្សា និងឆ្នាំ២០០៩ ត្រូវបានតំឡើងមុខងារជាប្រធានផ្នែកកម្មសិក្សា ។ នៅឆ្នាំ២០១១ ត្រូវបានផ្លាស់ប្តូរមុខងារជាប្រធានផ្នែកអភិបាលហ្វឹកហ្វឺន បន្ទាប់មកផ្លាស់ជា ប្រធានផ្នែកហ្វឹកហ្វឺនខាងក្រៅ នៅឆ្នាំ២០១២ ។ នៅក្នុងឆ្នាំ២០១៤ លោកស្រីមានតួនាទីជានាយិកាការិយាល័យសិក្សា និងកិច្ចការនិស្សិត នៃអេស៊ីលីដា គ្រេននីង សេនធ័រ។ បច្ចុប្បន្នលោកស្រីមានតួនាទីជាប្រធានការិយាល័យសិក្សា និងកិច្ចការនិស្សិត នៃវិទ្យាស្ថាន ពាណិជ្ជសាស្ត្រ អេស៊ីលីដា។

## លោក លឹម ឌីណា ប្រធានការិយាល័យទំនាក់ទំនងសាធារណៈ



ជនជាតិខ្មែរ កើតនៅឆ្នាំ១៩៨០។ លោកបានបញ្ចប់ថ្នាក់បរិញ្ញាបត្រជាន់ខ្ពស់ ផ្នែកគ្រប់គ្រងពាណិជ្ជកម្ម ជំនាញ ធនាគារ និងហិរញ្ញវត្ថុ ពីសាកលវិទ្យាល័យបៀលប្រាយនៅក្នុងឆ្នាំ២០១០ ។ លោកបានបញ្ចប់ថ្នាក់បរិញ្ញាបត្រគ្រប់គ្រង ពាណិជ្ជកម្ម ជំនាញគណនេយ្យ ពីវិទ្យាស្ថានជាតិគ្រប់គ្រងនៅក្នុងឆ្នាំ២០០២។ លោកធ្លាប់បានចូលរួមវគ្គទស្សនកិច្ចសិក្សានៅសាកលវិទ្យាល័យជាច្រើននៅតៃវ៉ាន់ ដូចជា ៖ Elite Study in Taiwan (ESIT) នៃក្រសួងអប់រំតៃវ៉ាន់, Chung Yuan Christian University (CYCU), National Cheng Kung University (NCKU), National Sun Yat-Sen University (NSYU), National Central University (NCU), National Taichung University of Education (NTUE), National Chung Hsing University (NCHU), and University of Taipei នៅក្នុងឆ្នាំ២០១៤។ នៅក្នុងខែវិច្ឆិកា ឆ្នាំ២០១៣ លោកក៏បានចូលរួមនៅក្នុងវគ្គសិក្ខាសាលាចែករំលែកបទពិសោធន៍ រវាង ធនាគារជាតិនៃប្រទេសកម្ពុជា និងធនាគារជាតិនៃសាធារណរដ្ឋប្រជាមានិតឡាវ ស្តីពីការគ្រប់គ្រង និងត្រួតពិនិត្យលើស្ថាប័នហិរញ្ញវត្ថុ នៅក្នុងប្រទេសកម្ពុជា និងសាធារណរដ្ឋប្រជាមានិតឡាវ។

លោកបានចូលបម្រើការងារជាមួយធនាគារ អេស៊ីលីដា នៅក្នុងឆ្នាំ២០០៨ ក្នុងមុខតំណែង ភ្នាក់ងារបម្រើអតិថិជន ហើយត្រូវបានដំឡើងមុខងារជា អនុប្រធានភ្នាក់ងារទីផ្សារសាខា នៅក្នុងខែតុលា ឆ្នាំ២០០៨។ នៅក្នុងខែមិថុនា ឆ្នាំ២០១១ លោកត្រូវបានតែងតាំងជា ប្រធានភ្នាក់ងារទីផ្សារសាខាក្រុងភ្នំពេញ។ នៅក្នុងខែកញ្ញា ឆ្នាំ២០១២ លោកត្រូវ បានផ្លាស់ប្តូរមុខងារជា ប្រធានផ្នែកទីផ្សារ នៃ អេស៊ីលីដា គ្រេននីង សេនធ័រ។ ចាប់ពីខែកក្កដា ឆ្នាំ២០១៦ មកដល់បច្ចុប្បន្ន លោកមានតួនាទីជា ប្រធានការិយាល័យទំនាក់ទំនងសាធារណៈ នៃ វិទ្យាស្ថានពាណិជ្ជសាស្ត្រ អេស៊ីលីដា ។

## លោកស្រី ហ៊ុំ ស្មើ ប្រធានដេប៉ាតឺម៉ង់គ្រប់គ្រងពាណិជ្ជកម្ម



កើតក្នុងឆ្នាំ១៩៧៩, ស្មើបានបញ្ចប់ថ្នាក់អនុបណ្ឌិតគ្រប់គ្រងពាណិជ្ជកម្ម ជំនាញគ្រប់គ្រង ពីសាកលវិទ្យាល័យបញ្ញាសាស្ត្រ នៅក្នុងឆ្នាំ ២០១៤។ លោកស្រីបានបញ្ចប់ថ្នាក់បរិញ្ញាបត្រគ្រប់គ្រងពាណិជ្ជកម្ម ជំនាញគណនេយ្យ ពីសាកលវិទ្យាល័យគ្រប់គ្រងនៅក្នុងឆ្នាំ២០០២, លោកស្រីក៏បានបញ្ចប់ថ្នាក់បរិញ្ញាបត្រវិទ្យាសាស្ត្រ ជំនាញគណិតវិទ្យា ពីសាកលវិទ្យាល័យភូមិន្ទភ្នំពេញ នៅក្នុងឆ្នាំ២០០០ និង ក្នុងឆ្នាំ២០០១ លោកស្រីបានទទួលសញ្ញាបត្រគ្រូមធ្យមសិក្សាទុតិយភូមិ ពីមហាវិទ្យាល័យគរុកោសល្យ ។

នៅក្នុងឆ្នាំ ២០១០ លោកស្រីបានចូលរួម វគ្គហ្វឹកហ្វឺនលើប្រធានបទ ការអភិវឌ្ឍសមត្ថភាពវិជ្ជាជីវៈ ជាមួយ Frankfurt School of Finance & Management និង នៅក្នុងឆ្នាំ ២០១១ លោកស្រីបានចូលរួម វគ្គហ្វឹកហ្វឺនលើប្រធានបទ ការបណ្តុះបណ្តាលគ្រូបង្រៀន ជាមួយ Frankfurt School of Finance & Management ។ នៅក្នុងឆ្នាំ ២០១៤ លោកស្រីបានចូលរួមវគ្គទស្សនកិច្ចសិក្សាទៅសាកលវិទ្យាល័យដែលល្បីៗ នៅ តៃវ៉ាន់ ដើម្បីសិក្សា អំពីប្រព័ន្ធអប់រំរបស់សាកលវិទ្យាល័យនីមួយៗ ទាក់ទងនឹងការគ្រប់គ្រង និស្សិត និងបណ្ណាល័យ។ នៅក្នុងឆ្នាំ ២០១៧ លោកស្រីបានចូលរួមវគ្គទស្សនកិច្ចសិក្សានៅ សាលាពាណិជ្ជសាស្ត្ររ៉ស នៃសាកលវិទ្យាល័យមីស៊ីហ្គែន ស្តីអំពីការបង្កើនសមត្ថភាព AIB ឱ្យក្លាយជាសាលាពាណិជ្ជកម្មឈានមុខគេនៅក្នុងប្រទេសកម្ពុជា ។

នៅក្នុងខែតុលា ឆ្នាំ២០០៤ លោកស្រីបានចូលបម្រើការងារជាបុគ្គលិកផ្នែកអភិវឌ្ឍន៍ហ្វឹកហ្វឺននៃធនាគារ អេស៊ីលីដា ភីអិលស៊ី ។ នៅឆ្នាំ២០០៨ លោកស្រីត្រូវបានតែងតាំងជា អនុប្រធានផ្នែកអភិវឌ្ឍន៍ហ្វឹកហ្វឺន និងឆ្នាំ២០០៩ ត្រូវបានដំឡើងមុខងារជាប្រធានផ្នែកអភិវឌ្ឍន៍ហ្វឹកហ្វឺន។ នៅឆ្នាំ២០១១ ត្រូវបានផ្លាស់ប្តូរមុខងារជាប្រធានផ្នែកស្រាវជ្រាវ និងអភិវឌ្ឍន៍ និងបន្ទាប់មកផ្លាស់ជាអ្នកឯកទេសជាន់ខ្ពស់ផ្នែកស្រាវជ្រាវ និងអភិវឌ្ឍន៍ នៅឆ្នាំ២០១៤។ ខែមីនា ឆ្នាំ២០១៦ ត្រូវបានផ្លាស់ប្តូរមុខងារជាជំនួយការដេប៉ាតឺម៉ង់គ្រប់គ្រងពាណិជ្ជកម្ម និងបន្ទាប់មក លោកស្រីត្រូវបានដំឡើងមុខងារជា ប្រធានដេប៉ាតឺម៉ង់គ្រប់គ្រងពាណិជ្ជកម្ម នៅខែមិថុនា ឆ្នាំ២០១៦ រហូត ដល់ខែមករាឆ្នាំ២០១៧ ។ បច្ចុប្បន្នលោកស្រីមានតួនាទីជា ប្រធានមជ្ឈមណ្ឌលសម្រាប់គរុកោសល្យនវានុវត្តន៍ ។

# ទីប្រឹក្សា

ទីប្រឹក្សា នៃ វិទ្យាស្ថាន ពាណិជ្ជសាស្ត្រ អេស៊ីលីដា មានកាតព្វកិច្ចបំពេញតួនាទីឱ្យអស់ពីសមត្ថភាព ដើម្បីចូលរួមត្រួតពិនិត្យកែតម្រូវ និងផ្តល់យោបល់អភិវឌ្ឍធ្វើយ៉ាងណា ឱ្យសម្រេចនូវគោលដៅយុទ្ធសាស្ត្រ របស់ វិទ្យាស្ថាន ពាណិជ្ជសាស្ត្រ អេស៊ីលីដា មានដូចជា៖

- ផ្តល់ការប្រឹក្សាយោបល់លើការរៀបចំផែនការ និងយុទ្ធសាស្ត្រដើម្បីដំណើរការ វិទ្យាស្ថាន ពាណិជ្ជសាស្ត្រ អេស៊ីលីដា ជាស្ថាប័នបុត្រសម្ព័ន្ធ ធនាគារ អេស៊ីលីដា ភីអិលស៊ី ប្រកបអាជីវកម្មដាច់ដោយឡែកប្រកបដោយនិរន្តរភាព ។
- ផ្តល់ការប្រឹក្សាយោបល់ លើការងារបណ្តុះបណ្តាល គ្រប់គ្រងប្រតិបត្តិការ និងការងារទំនាក់ទំនងសាធារណៈ ដើម្បីប្រែ វិទ្យាស្ថាន ពាណិជ្ជសាស្ត្រ អេស៊ីលីដា ទៅជាគ្រឹះស្ថានឧត្តមសិក្សាឈានមុខនៅក្នុងតំបន់ ។
- ផ្តល់ការបណ្តុះបណ្តាល ផ្ទេរបទពិសោធន៍ និងចំណេះដឹង ដល់អ្នកពាក់ព័ន្ធ ដើម្បីពង្រឹង សមត្ថភាព និងពង្រឹងប្រតិបត្តិការ វិទ្យាស្ថាន ពាណិជ្ជសាស្ត្រ អេស៊ីលីដា ។

## លោក ថោង ចាន់តារា ទីប្រឹក្សា



ជនជាតិខ្មែរ កើតថ្ងៃទី២៥ ខែធ្នូ ឆ្នាំ១៩៦០ ។ លោកទទួលបានបរិញ្ញាបត្រអប់រំ នៅមហាវិទ្យាល័យ Advanced Education នៅប្រទេសថៃ ឆ្នាំ១៩៩២ ។

ចាប់ពីឆ្នាំ១៩៩៤មក លោកបានចូលរួមវគ្គបណ្តុះបណ្តាលជាច្រើន នៅក្នុងវិស័យ ធនាគារ មីក្រូហិរញ្ញវត្ថុ និងសហគ្រាសខ្នាតតូច និងមធ្យមនៅក្នុងប្រទេស និងនៅបណ្តាប្រទេសមួយចំនួនដូចជា៖ សហរដ្ឋអាមេរិក ថៃ ហុងកុង សិង្ហបុរី ហ្វីលីពីន ឥណ្ឌូណេស៊ី មីយ៉ាន់ម៉ា ឡាវ ។ ក្នុងឆ្នាំ១៩៩៩ លោកបានបញ្ចប់វគ្គគ្រប់គ្រង ស្តីពីស្ថាប័នហិរញ្ញវត្ថុសម្រាប់អភិវឌ្ឍន៍ សហគ្រាសឯកជន(FIPED) នៅសាកលវិទ្យាល័យ Harvard សហរដ្ឋអាមេរិក។

ចាប់ពីឆ្នាំ១៩៩៤ លោកបានបម្រើការងារជាមួយ អង្គការ អេស៊ីលីដា ជាភ្នាក់ងារផ្សព្វផ្សាយសហគ្រាសខ្នាតតូច(SEPO) និងជាភ្នាក់ងារឥណទាន ។ ក្នុងឆ្នាំ១៩៩៥ លោកត្រូវបានតែងតាំងជា នាយករង អេស៊ីលីដា សាខាខេត្តបាត់ដំបង ។ នៅក្នុង១៩៩៧ លោកជានាយក អេស៊ីលីដា សាខាខេត្តកំពង់ធំ ។ ឆ្នាំ២០០១ លោកជាប្រធានផ្នែកធនធានមនុស្ស នៅការិយាល័យកណ្តាល ធនាគារ អេស៊ីលីដា ភីអិលស៊ី ។ ក្នុងឆ្នាំ២០០២ លោកជាប្រធានផ្នែកហ្វឹកហ្វឺន និងជានាយកការិយាល័យហ្វឹកហ្វឺន នៅឆ្នាំ២០០៦ ហើយលោកត្រូវបានតែងតាំងជា នាយកនាយកដ្ឋានហ្វឹកហ្វឺន ចាប់ពីឆ្នាំ២០០៩ ដល់ ខែកក្កដា ឆ្នាំ២០១១ ។ ចាប់ពីខែសីហា ឆ្នាំ២០១១ ដល់ឆ្នាំ ២០១៥ លោកមានតំណែងជា ទីប្រឹក្សា នៃ អេស៊ីលីដា ត្រេននីង សេនធ័រ ។ ចាប់ពីខែមករា ឆ្នាំ២០១៦ រហូតមកដល់បច្ចុប្បន្ន លោកមានតំណែងជា ទីប្រឹក្សា នៃវិទ្យាស្ថាន ពាណិជ្ជសាស្ត្រ អេស៊ីលីដា ។

## លោក ម៉ែន សុផល ទីប្រឹក្សា



ជនជាតិខ្មែរ កើតថ្ងៃទី០១ ខែមករា ឆ្នាំ១៩៥៨។ លោកបានទទួល សញ្ញាបត្របណ្តុះបណ្តាលជំនាញគ្រូហ្វឹកហ្វឺន នៅឆ្នាំ២០១១ ពី Frankfurt School of Finance & Management សញ្ញាបត្របណ្តុះបណ្តាលជំនាញរៀបចំ និងអភិវឌ្ឍន៍កម្មវិធីហ្វឹកហ្វឺន នៅឆ្នាំ២០១១ ពី Robenny School of Business សញ្ញាបត្របណ្តុះបណ្តាលជំនាញគ្រូហ្វឹកហ្វឺន នៅឆ្នាំ២០០៦ ពីACE, សញ្ញាបត្រគ្រូហ្វឹកហ្វឺនគ្រូ នៅឆ្នាំ១៩៨៩, សញ្ញាបត្រគរុកោសល្យនៅឆ្នាំ១៩៩០ ពីមជ្ឈមណ្ឌលហ្វឹកហ្វឺនគ្រូ នៅប្រទេសថៃ ។

លោកបានចូលរួមវគ្គបណ្តុះបណ្តាលជាច្រើន នៅក្នុងវិស័យ ធនាគារ មីក្រូហិរញ្ញវត្ថុ និងសហគ្រាសខ្នាតតូច និង មធ្យម នៅក្នុងប្រទេស និងនៅបណ្តាប្រទេស មួយចំនួនដូចជា ៖ នៅប្រទេសថៃ ចិន ឥណ្ឌូណេស៊ី ហ្វីលីពីន អ៊ីតាលី អាល្លឺម៉ង់ ។

លោកបានចូលបម្រើការងារជាមួយ អេស៊ីលីដា នៅឆ្នាំ១៩៩៣ ជាភ្នាក់ងារផ្សព្វផ្សាយសហគ្រាសខ្នាតតូច និងជាគ្រូហ្វឹកហ្វឺន។ ឆ្នាំ១៩៩៤ លោកបានផ្លាស់មកបំពេញការងារជា អ្នកឯកទេសសហគ្រាសខ្នាតមធ្យម និងក្រុមគាំទ្របច្ចេកទេស។ នៅឆ្នាំ១៩៩៨ លោកត្រូវបានតែងតាំងជា នាយកមជ្ឈមណ្ឌលហ្វឹកហ្វឺន អេស៊ីលីដា។ ឆ្នាំ២០០០ លោកត្រូវបានតែងតាំងជានាយករងនាយកដ្ឋានឥណទាន។ ចាប់តាំងពីឆ្នាំ២០០១មក លោកត្រូវបានចាត់តាំងឱ្យកាន់មុខតំណែងជា អ្នកគ្រប់គ្រងជំនាញដទៃទៀតជាច្រើន។ ក្នុងឆ្នាំ២០០៩ លោកត្រូវបានតែងតាំងជា នាយកការិយាល័យសិក្សា នៃនាយកដ្ឋានហ្វឹកហ្វឺន ធនាគារ អេស៊ីលីដា និងបន្ទាប់មកជា នាយករងនាយកដ្ឋានហ្វឹកហ្វឺន ធនាគារ អេស៊ីលីដា នៅឆ្នាំ ២០១១ ។ នៅឆ្នាំ២០១២ លោកមានតំណែងជា នាយកនាយកដ្ឋានហ្វឹកហ្វឺន នៃ អេស៊ីលីដា ត្រេននីង សេនធ័រ ។ ឆ្នាំ២០១៣ លោកទទួលមុខតំណែងជា នាយកការិយាល័យសិក្សា និងចាប់ពីដើមឆ្នាំ២០១៤ ដល់ឆ្នាំ ២០១៥ លោកមានតំណែងជា ទីប្រឹក្សា នៃអេស៊ីលីដា ត្រេននីង សេនធ័រ ។ ចាប់ពីខែមករា ឆ្នាំ២០១៦ រហូតមកដល់បច្ចុប្បន្ន លោកមានតំណែងជា ទីប្រឹក្សា នៃវិទ្យាស្ថាន ពាណិជ្ជសាស្ត្រ អេស៊ីលីដា ។

# ក្រមប្រតិបត្តិ

ក្នុងក្រមប្រតិបត្តិ របស់ក្រុមប្រឹក្សាភិបាល គ្រប់គ្រងដោយ ៖

១. អនុស្សរណៈ និងលក្ខន្តិកៈរបស់ វិទ្យាស្ថាន ពាណិជ្ជសាស្ត្រ អេស៊ីលីដា

២. កិច្ចព្រមព្រៀងភាគទុនិក និង

៣. ច្បាប់ និងបទបញ្ញត្តិទាំងឡាយណាដែលពាក់ព័ន្ធរបស់ព្រះរាជាណាចក្រកម្ពុជា

វិវឌ្ឍនាការឥតឈប់ឈររបស់ វិទ្យាស្ថាន ពាណិជ្ជសាស្ត្រ អេស៊ីលីដា គឺទាមទារឲ្យមានការយកចិត្តទុកដាក់ខ្ពស់ ដើម្បីធានាថា បទដ្ឋាននៃការអនុវត្តផ្ទៃក្នុងរបស់សាជីវកម្ម ត្រូវបានរក្សាក្នុងកម្រិតមួយខ្ពស់បំផុត ។ ក្នុងចំណោមបញ្ហាផ្សេងៗនោះ រួមមាន៖ កិច្ចព្រមព្រៀងលើការផ្តល់សេវារបស់ក្រុមប្រឹក្សាភិបាល កម្មវិធីបណ្តុះបណ្តាល តួនាទីមុខងាររបស់ក្រុមប្រឹក្សាភិបាល បញ្ជីវាយតម្លៃក្រុមប្រឹក្សាភិបាល និងក្រមប្រតិបត្តិរបស់ក្រុមប្រឹក្សាភិបាល ត្រូវបានរៀបចំដាក់ឲ្យប្រើប្រាស់ ហើយតួនាទីទាក់ទងទៅនឹងប្រាក់លាភការ និងការចំណាយរបស់ក្រុមប្រឹក្សាភិបាល ត្រូវបានរៀបចំជាទម្រង់យ៉ាងច្បាស់លាស់ ។

និយោជិតគ្រប់រូបរបស់ វិទ្យាស្ថាន ពាណិជ្ជសាស្ត្រ អេស៊ីលីដា ស្ថិតក្រោមការគ្រប់គ្រងមួយយ៉ាងតឹងរឹងនៃ ក្រមសីលធម៌ដែលបានកំណត់ក្នុងអនុសញ្ញារួមការងារ ដោយគ្របដណ្តប់លើបញ្ហាមួយចំនួន ដូចជា៖ ចរិត លក្ខណបុគ្គល ទំនាក់ទំនងជាមួយអ្នករួមការងារ អតិថិជន និងអ្នកគ្រប់គ្រង អាថ៌កំបាំងវិជ្ជាជីវៈ វិវាទលើផលប្រយោជន៍ ការទទួលយកអំណោយ ការសម្អាតប្រាក់ និងការបកអាក្រាតកំហុសឆ្គង ។

ឯកសារទាំងនេះ ត្រូវបានត្រួតពិនិត្យសារឡើងវិញយ៉ាងទៀងទាត់ដោយសវនករ ដើម្បីធានាថា វានៅតែ មានសុពលភាពប្រើប្រាស់ និងទាន់សម័យ ។



ការរំលឹកគុណមាតា-បិតា មុនពិធីបើកវគ្គសិក្សាអប់រំ





សកម្មភាពបរិច្ចាគឈាមរបស់ថ្នាក់ដឹកនាំ និងកម្មករនិយោជិត ព្រមទាំងនិស្សិត វិទ្យាស្ថាន ពាណិជ្ជសាស្ត្រ អេស៊ីលីដា

# ការិយាល័យកណ្តាលធនាគារ អេស៊ីលីដា និងបុត្រសម្ព័ន្ធ

## ព្រះរាជាណាចក្រកម្ពុជា

### ធនាគារ អេស៊ីលីដា ភីអិលស៊ី



### ការិយាល័យកណ្តាល

អគារលេខ៦១ មហាវិថីព្រះមុនីវង្ស សង្កាត់ស្រះចក ខណ្ឌដូនពេញ រាជធានីភ្នំពេញ ។
ប្រអប់សំបុត្រលេខ ៖ ១១៤៩
ទូរស័ព្ទ ៖ ០២៣ ៩៩៨ ៧៧៧ / ៤៣០ ៩៩៩
ទូរសារ ៖ ០២៣ ៤៣០ ៥៥៥
អ៊ីម៉ែល ៖ acledabank@acledabank.com.kh
វេបសាយ ៖ www.acledabank.com.kh
SWIFT Code: ACLBKHPP
ការិយាល័យទំនាក់ទំនងអតិថិជន (បម្រើ ២៤ម៉ោង)
ទូរស័ព្ទ ៖ ០២៣ ៩៩៤ ៤៤៤, ០១៥ ៩៩៩ ២៣៣
អ៊ីម៉ែល ៖ inquiry@acledabank.com.kh

### អេស៊ីលីដា ស៊ីឃ្យូរីធី ភីអិលស៊ី

អគារការិយាល័យកណ្តាល ធនាគារ អេស៊ីលីដា ភីអិលស៊ី (ជាន់ទី៥) អគារលេខ៦១
មហាវិថីព្រះមុនីវង្ស សង្កាត់ស្រះចក ខណ្ឌដូនពេញ រាជធានីភ្នំពេញ ។
ទូរស័ព្ទ ៖ ០២៣ ៩៩៩ ៩៦៦ / ៩៩៩ ៩៧៧ / ៧២៣ ៣៨៨, ០១៥ ៧២៣ ៣៨៨
អ៊ីម៉ែល ៖ info@acledasecurities.com.kh
វេបសាយ ៖ www.acledasecurities.com.kh

### អេស៊ីលីដា ប្រូភើធី អិលធីឌី

អគារលេខ៦១ មហាវិថីព្រះមុនីវង្ស សង្កាត់ស្រះចក ខណ្ឌដូនពេញ រាជធានីភ្នំពេញ ។
ប្រអប់សំបុត្រលេខ ៖ ១១៤៩
ទូរស័ព្ទ ៖ ០២៣ ៩៩៨ ៧៧៧ / ៤៣០ ៩៩៩
ទូរសារ ៖ ០២៣ ៤៣០ ៥៥៥
អ៊ីម៉ែល ៖ acp@acledabank.com.kh

### វិទ្យាស្ថាន ពាណិជ្ជសាស្ត្រ អេស៊ីលីដា



អគារលេខ១៣៩៧ មហាវិថីមិត្តភាព ភ្នំពេញ-ហាណូយ ភូមិអន្លង់ក្ងាន
សង្កាត់ឃ្មួញ ខណ្ឌសែនសុខ រាជធានីភ្នំពេញ ព្រះរាជាណាចក្រកម្ពុជា ។
ទូរសារ ៖ ០២៣ ៩៩៩ ៩៧៩ / ៩៨៦ ៩៣៧
អ៊ីម៉ែល ៖ info@acleda-aib.edu.kh
វេបសាយ ៖ www.acleda-aib.edu.kh

## សាធារណរដ្ឋប្រជាធិបតេយ្យប្រជាមានិតឡាវ

### ធនាគារ អេស៊ីលីដា ឡាវ



### Headquarters

#372, Corner of Dongpalane and Dongpaina Road, Unit 21,
Phonesavanh Neua Village, Sisattanak District, Vientiane Capital.
P.O. Box: 1555
Tel: +856 (0)21 264 994 / 264 998
Fax: +856 (0)21 264 995
E-mail: acledabank@acledabank.com.la
Website: www.acledabank.com.la
SWIFT: ACLBLALA

## សហភាពមីយ៉ាន់ម៉ា

### ស្ថាប័នមីក្រូហិរញ្ញវត្ថុ អេស៊ីលីដា មីយ៉ាន់ម៉ា



#### Headquarters / Yangon Branch

Building No.186(B), Shwe Gon Taing Road, Yae Tar Shae Block,
Bahan Township, Yangon Region.
Tel: (+95-1) 559 475 / 552 956
Website: www.acledamfi.com.mm

# សកម្មភាពអប់រំបណ្តុះបណ្តាល



ពិធីបើកវគ្គទស្សនកិច្ចសិក្សា សម្រាប់ប្រតិបត្តិករមីក្រូហិរញ្ញវត្ថុមកពីប្រទេសចិន ក្រោមអធិបតីភាព លោកប្រធាននាយកប្រតិបត្តិ ធនាគារ អេស៊ីលីដា ភីអិលស៊ី



ទស្សនកិច្ចសិក្សាសិក្ខាមមកពីប្រទេសអេហ្ស៊ីប នៅ ធនាគារ អេស៊ីលីដា ភីអិលស៊ី សាខាស្រុកមុខកំពូល



សិក្ខាកាមមកពីប្រទេសម៉ុងតេណេហ្គ្រោ ធ្វើទស្សនកិច្ចសិក្សានៅការិយាល័យកណ្តាល ធនាគារ អេស៊ីលីដា ភីអិលស៊ី


សិក្ខាកាមមកពីក្រុមហ៊ុន KB Microfinance Myanmar Co., Ltd ចុះធ្វើទស្សនកិច្ចសិក្សា នៅធនាគារ អេស៊ីលីដា ភីអិលស៊ី



សកម្មភាពគ្រូកំពុងពន្យល់មេរៀនដល់និស្សិតនៅក្នុងថ្នាក់



សកម្មភាពគ្រូកំពុងបង្ហាត់បង្រៀនដល់និស្សិតនៅក្នុងថ្នាក់



សកម្មភាពគ្រូកំពុងប្រាប់ពីរបៀបធ្វើ Assignments ដល់និស្សិត



សកម្មភាពនិស្សិតសួរសំណួរទៅកាន់គ្រូ



សកម្មភាពអប់រំច្បាប់ចរាចរដល់និស្សិត



សកម្មភាពនិស្សិតសិក្សាមុខវិជ្ជាកុំព្យូទ័រ



សកម្មភាពគ្រូជួយពន្យល់មេរៀនដល់និស្សិតក្រៅម៉ោងសិក្សា



សកម្មភាពនិស្សិតកំពុងប្រឡងក្នុងថ្នាក់



សកម្មភាពនិស្សិត វិទ្យាស្ថាន ពាណិជ្ជសាស្ត្រ អេស៊ីលីដា ជួបជាមួយ បណ្ឌិត John Branch នៃ Ross School of Business, University of Michigan សហរដ្ឋអាមេរិក



និស្សិតវិទ្យាស្ថាន ពាណិជ្ជសាស្ត្រ អេស៊ីលីដា មានចំណាប់អារម្មណ៍ចំពោះបបកថា របស់ បណ្ឌិត អ៊ិន ចាន់នី ប្រធាននាយកប្រតិបត្តិធនាគារ អេស៊ីលីដា ភីអិលស៊ី




និស្សិត AIB ចូលរួមកម្មវិធីការប៉ុនប៉ងជាផ្លូវការ ដើម្បីបំបែកកំណត់ត្រាពិភពលោកហ្គីណេស (Guinness) ស្តីអំពីសិក្ខាសាលាធុរកិច្ចអនុវត្តន៍ជាក់ស្តែងដ៏ធំបំផុត




សកម្មភាពនិស្សិតចូលរួមផ្សព្វផ្សាយថ្នាក់បរិញ្ញាបត្រ និងបរិញ្ញាបត្ររង របស់ វិទ្យាស្ថាន ពាណិជ្ជសាស្ត្រ អេស៊ីលីដា



សកម្មភាពនិស្សិតវិទ្យាស្ថាន ពាណិជ្ជសាស្ត្រ អេស៊ីលីដា ចូលរួមចែកអំណោយសិក្សា ដល់សិស្សវិទ្យាល័យ



សកម្មភាព គ្រូ និងនិស្សិត ចូលរួមកម្មវិធីហ្វឹកហាត់ YOGA នៅវិទ្យាស្ថាន ពាណិជ្ជសាស្ត្រ អេស៊ីលីដា



សកម្មភាពនិស្សិត វិទ្យាស្ថាន ពាណិជ្ជសាស្ត្រ អេស៊ីលីដា ចូលរួមដំណើរទស្សនកិច្ចសិក្សា ទៅកាន់ប្រាសាទសំបូរព្រៃគុក ខេត្តកំពង់ធំ



សកម្មភាពថ្នាក់ដឹកនាំ និងនិស្សិតវិទ្យាស្ថាន ពាណិជ្ជសាស្ត្រ អេស៊ីលីដា ចូលរួមចែកអំណោយសិក្សា ដល់សិស្សវិទ្យាល័យ



ថ្នាក់ដឹកនាំវិទ្យាស្ថានថតរូបអនុស្សាវរីយ៍ ជាមួយនិស្សិត ក្នុងពិធីបុណ្យចូលឆ្នាំថ្មី ប្រពៃណីជាតិខ្មែរ




អគារលេខ១៣៩៧ មហាវិថីមិត្តភាព ភ្នំពេញ-ហាណូយ
ភូមិអន្លង់ក្ងាន សង្កាត់ឃ្មួញ ខណ្ឌសែនសុខ
រាជធានីភ្នំពេញ ព្រះរាជាណាចក្រកម្ពុជា

០២៣ ៩៩៩ ៩៤៤ / ៩៨៦ ៩៣៧

www.acleda-aib.edu.kh

info@acleda-aib.edu.kh

ACLEDA INSTITUTE OF BUSINESS


ទីតាំងអគារថ្មីរបស់ វិទ្យាស្ថាន ពាណិជ្ជសាស្ត្រ អេស៊ីលីដា ស្ថិតនៅ អគារលេខ១៣៩៧ មហាវិថីមិត្តភាព ភ្នំពេញ-ហាណូយ ភូមិអន្លង់ក្ងាន សង្កាត់ឃ្មួញ ខណ្ឌសែនសុខ រាជធានីភ្នំពេញ ខាងក្រោយទីក្រុងរណប Grand Phnom Penh នឹងចាប់ដំណើរការជាផ្លូវការនៅចុងឆ្នាំ២០១៨